សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite’ Royale de droit et des Sciences Economiques
Royal university of law and economics

**សារណាបញ្ចប់ការសិក្សា**

# ការប្រាក់

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **លោក ពេជ្រ សុមិនា**

**លោក ម៉េង ចាន់ថេង**

សាស្ត្រាចារ្យណែនាំ៖

**លោក គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០១៣

ជំនាន់ទី១៧

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

តាមរយៈស្នាដៃសារណាបញ្ចប់ការសិក្សានៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ យើងខ្ញុំ **ពេជ្រ សុមិនា** និង **ម៉េង ចាន់ថេង** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមលំឱនកាយគោរពដោយក្តីកត្តញ្ញូតាធម៌ និង សេចក្តីដឹងគុណយ៉ាងជ្រាលជ្រៅ

**ជូនចំពោះ**

អ្នកមានគុណរបស់យើងខ្ញុំទាំងពីរ - លោកឪពុក **ពេជ្រ គង់ អ្នកម្តាយ ជួន សុភាព**

- លោកឪពុក **ជឹម ម៉េង អ្នកម្តាយចេង ចាន់ថុល**

ដែលលោកបានផ្តល់កំណើតដល់កូនទាំងពីរ និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ការអប់រំទូន្មាន និងឧបត្ថម្ភផ្គត់ផ្គង់ដល់យើងខ្ញុំជាសំភារៈ ហិរញ្ញវត្ថុ កំលាំងចិត្ត សព្វគ្រប់បែបយ៉ាង ក្នុងជំរុញឲ្យការសិក្សារបស់យើងខ្ញុំរហូតទទួលបានជោគជ័យ ។

លោកសាស្ត្រាចារ្យណែនាំ **គង់ សុភ័ក្រ្ត** ដែលបានបង្ហាត់បង្ហាញទាំងជំនាញ ទាំងសីលធម៌ និងដឹកនាំ ផ្តល់ដំបូងន្មានល្អៗ ក្នុងរយៈពេលជិត ២ឆ្នាំនេះ រួមទាំងការជ្រោមជ្រែងក្នុងការសសេរ សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះអោយចប់ជាស្ថាពរ ។

រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជា មគ្គុទេសន៍ដ៏ឆ្លៀសវៃ ក្នុងការផ្តល់ជូនសន្តិភាព ស្ថេរភាពសង្គម ភាពរីកចម្រើនជឿនលឿន បង្កើត បាននូវសក្តានុពលលើវិស័យអប់រំ ដល់ប្រជាពលរដ្ឋ ទូទាំងប្រទេស រួមទាំងយើងខ្ញុំទាំងពីរនាក់ផងដែរ ។

ចុងក្រោយ យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ មិត្តភក្តិទាំងអស់ បងប្រុស បងស្រី ព្រមសិស្សច្បងដែលបានចូលរួមជ្រោមជ្រែងជាសម្ភារៈជាគំនិតយោបល់បទពិសោធន៍ ជាពិសេសលោកគ្រូ អ្នកគ្រូដែលបានខិតខំបង្រៀន ផ្តល់ចំណេះដឹង និងការទូន្មានល្អៗដល់យើងទាំងពីរអស់រយៈពេលបួនឆ្នាំ ។

សូមអស់លោក អ្នកទទួលបានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្នុងឆ្នាំបញ្ចប់នៃថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដោយឆ្លងកាត់ការសិក្សា ទ្រឹស្តីអស់រយៈពេលបួនឆ្នាំពេញ ជាលក្ខខណ្ឌដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ សាកលវិទ្យាល័យបានតម្រូវឲ្យនិស្សិតធ្វើការសរសេរ « **សារណា** » ដើម្បីជាសាក្ខីកម្មនៃចំណេះដឹងពិតរបស់និស្សិត និង បន្សល់ទុកស្នាដៃជាឯកសារសម្រាប់ស្រាវជ្រាវបន្ត។

តបតាមការលើកបង្ហាញខាងលើ និង ការពិភាក្សាជាមួយដៃគូ ពិសេសមានការណែនាំពីសាស្ត្រាចារ្យ **គង់ សុភ័ក្ត្រ** នត្ថិភាពនៃប្រធានបទមួយបានកើតឡើងគឺ « **ការប្រាក់** » ។ ឈរលើសារៈសំខាន់នៃប្រធាននេះ ចំពោះជីវភាពប្រចាំថ្ងៃ ដោយភាពស្រពិចស្រពិល ក្រុមយើងខ្ញុំបានខិតខំ បានយ៉ាងស្រស្រាក់ស្រស្រាំ ប្រើប្រាស់អស់លទ្ធភាពនៃចំណេះដឹងដែលមានស្រាប់ និងការស្រាវជ្រាវបន្ថែម ព្រមទាំងការណែនាំដ៏ធំធេងរបស់សាស្ត្រាចារ្យដឹកនាំ ដើម្បីចងក្រងជាសារណានេះឡើង។ ស្របតាមបរិបទនៃសង្គមបច្ចុប្បន្ន មិនថាជាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជា ឬក្នុងក៏បណ្តាប្រទេសរីកចម្រើននោះទេ ការខ្ចីប្រាក់គឺមានច្រើនជាងសម័យសេដ្ឋកិច្ចបូរាណទៅទៀត ទោះក្នុង វិស័យបរិក្ខា ការហូបចុក ពាណិជ្ជកម្ម ។ល។ ដូច្នេះបំណុលទាំងនោះត្រូវមានតម្លៃតបពោលគឺ « **ការប្រាក់** » នេះឯង អ្វីដែលរឹតតែចាប់អារម្មណ៍ សួរថា យើងបានដឹងអ្វីខ្លះពីការប្រាក់ ? តើការប្រាក់ត្រូវបានកំណត់ និងបង្កើតឡើងយ៉ាងដូចម្តេច ? តើនៅពេលមានវិវាទត្រូវធ្វើយ៉ាងម្តេច ? ប្រធានបទ ការប្រាក់នេះនឹងលើបញ្ជាក់ឲ្យបានកាន់តែច្បាស់ អំពីប្រតិបត្តិការជាក់ស្តែងក្នុងការអនុវត្តក្នុងពេលបច្ចុប្បន្ន និង មូលដ្ឋាននៃនីតិនានា រួមទាំងវិធាននានាដែលពាក់ព័ន្ធយកមកធ្វើការបកស្រាយ ក្នុងគោលបំណងលុបបំបាត់ភាពស្រពិចស្រពិលនានាកន្លងមកពាក់ព័ន្ធនឹង « **ការប្រាក់** » នេះនឹងផ្តល់ជាដំណោះស្រាយមួយយ៉ាងប្រសើរក្នុងវិស័យខ្ចីបរិភោគនៅកម្ពុជា ។ យ៉ាងណាមិញ ទោះបីជាស្នាដៃនេះ ត្រូវបានឧប្បត្តិកឡើងដោយឆ្លងកាត់ការពិភាក្សា និង ពិនិត្យយ៉ាងម៉ត់ចត់យ៉ាងណាក៏ដោយ យើងជឿជាក់ថា នៅមានចំណុចខ្វះខាតជាច្រើនទៀត ។

ជាទីបញ្ចប់យើងខ្ញុំទាំងអស់គ្នា រង់ចាំទទួលការផ្តល់មតិយោបល់ និង ការរិះគន់ស្ថាបនាអំពីសំណាក់លោកសាស្ត្រាចារ្យ និស្សិត និង លោកអ្នកអានទាំងឡាយ ដោយសោមនស្សរីករាយ ដើម្បីអោយស្នាដៃមួយនេះកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត៕

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**......១

## ជំពូកទី១

## មូលដ្ឋាននៃការប្រាក់

**១.១ សញ្ញាណទូទៅស្តីពីការប្រាក់**......៣

១.១.១ និយមន័យនៃការប្រាក់......៣

១.១.២ ប្រភពនៃការប្រាក់......៤

**១.២ បទដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង**......៦

១.២.១ បរិបទនៃការបែងចែកការគ្រប់គ្រង......៦

១.២.២ បទដ្ឋានគតិយុត្តិគ្រប់គ្រងចំពោះកិច្ចរដ្ឋប្បវេណី......៧

១.២.៣ បទដ្ឋានគតិយុត្តិគ្រប់គ្រងចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ......៨

១.២.៤ អន្តរកាលក្នុងការគ្រប់គ្រង......៩

## ជំពូកទី២

## ការប្រាក់កំណត់ក្នុងកិច្ចរដ្ឋប្បវេណី

**១.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់**......១០

១.១.១ និយមន័យនៃអត្រាការប្រាក់កំណត់ដោយច្បាប់......១០

១.១.២ ប្រភេទផ្សេងៗនៃអត្រាការប្រាក់ដែលកំណត់ដោយច្បាប់......១១

**១.២ អត្រាការប្រាក់ដែលកំណត់តាមកិច្ចសន្យា**......១៣

១.២.១ និយមន័យនៃអត្រាការប្រាក់ក្នុងកិច្ចសន្យា......១៣

១.២.២ ប្រភេទនៃអត្រាការប្រាក់តាមកិច្ចសន្យា......១៦

១.២.២.១ អត្រាការប្រាក់ធម្មតាដែលត្រូវបានកម្រិត ........................................ ១៦

១.២.២.២ អត្រាការប្រាក់យឺតយ៉ាវ.............................................................. ១៧

១.២.២.៣ អត្រាការប្រាក់បង្គរ ឬ ការប្រាក់សមាស........................................ ១៨

**១.៣ ពេលវេលា និង ទីកន្លែងនៃការបង់ការប្រាក់** ........................................ ១៨

១.៣.១ ពេលវេលា ............................................................................ ១៨

១.៣.២ ទីកន្លែងនៃការសងការប្រាក់............................................................ ២០

## ជំពូកទី៣

## ការប្រាក់ដែលកំណត់ដោយធនាគារជាតិអនុវត្ត

## សម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

**១.១ អត្រាការប្រាក់ដែលកំណត់មុនការប្រកាសអំពីពិដានអត្រាការប្រាក់** ................... ២១

១.១.១ ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ........................................ ២១

១.១.២ មូលដ្ឋានក្នុងការកំណត់អត្រាការប្រាក់.................................................. ២៣

១.១.២.១ ប្រភពទុន ........................................................................ ២៣

១.១.២.២ តម្លៃប្រតិបត្តិការ.................................................................. ២៤

១.១.២.៣ កម្រិតហានិភ័យ .................................................................. ២៤

១.១.២.៤ ស្ថានភាពទីផ្សារ.................................................................. ២៥

**១.២ ការកំណត់ពិដានអត្រាការប្រាក់**.......................................................... ២៥

១.២.១ បុព្វហេតុនៃការកំណត់ពិដានអត្រាការប្រាក់ ........................................ ២៦

១.២.២ វិសាលភាពនៃការអនុវត្ត.................................................................. ២៦

១.២.៣ ទោសទណ្ឌ.................................................................................. ២៧

១.២.៤ គតិយុត្តិភាពនៃការអនុវត្ត ................................................................ ២៨

១.២.៤.១ នីតិកម្ម ............................................................ ២៨
១.២.៤.២ ត្រួតពិនិត្យដល់ទីកន្លែង ............................................................ ២៩
១.២.៤.៣ ត្រួតពិនិត្យឯកសារ ............................................................ ២៩
១.២.៥ ផលវិបាកនៃការអនុវត្តការដាក់ពិដានអត្រាការប្រាក់ ............................................................ ៣០
១.២.៥.១ គុណសម្បត្តិ ............................................................ ៣០
១.២.៥.២ គុណវិបត្តិ ............................................................ ៣១
**១.៣ ការគណនាការប្រាក់ឥណទាន** ............................................................ ៣២
– **សេចក្ដីសន្និដ្ឋាន** ............................................................ ៣៥
– **ឯកសារយោង**
– **ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ពាក្យថា « **ការប្រាក់** » យើងតែងបានឮជាញឹកញាប់ ជាពិសេសរយៈពេលចុងក្រោយនេះ ពោលគឺ នៅក្រោយពីមានការផ្តល់អនុសាសន៍ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល អំពីការទម្លាក់អត្រាការប្រាក់ ។ ពេលនោះហើយដែលយើងឃើញថាការប្រាក់ហាក់ដូចជា ក្លាយជាប្រធានបទមួយ ដែលទទួលបានការចាប់អារម្មណ៍ខ្លាំងពីសំណាក់មហាជនទូទៅ ស្ទើរគ្រប់ពេល គ្រប់ទីកន្លែង គ្រប់ពេលជួបជុំគ្នា គេតែងជជែកពិភាក្សាគ្នាអំពីរឿងការប្រាក់ ។ ទោះបីជាមានការជជែកពិភាក្សាយ៉ាងណាក៏ដោយក៏នៅតែមានអ្នកមួយចំនួនមិនទាន់បានស្គាល់ច្បាស់ថាអ្វីជាការប្រាក់? តើនរណាជាអ្នកកំណត់ អត្រាការប្រាក់ ? ហើយចុះតើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង អ្នកចងការប្រាក់ឯកជនមានការកំណត់អត្រាការប្រាក់ដូចគ្នាដែរឬទេ ? សំនួរទាំងនេះ មានមនុស្សមួយចំនួនប្រហែលជាពិបាកឆ្លើយបន្តិច ក៏ព្រោះតែការប្រាក់តែមួយម៉ាត់ វាមានវិសាលភាពធំធេងណាស់ ដែលទាមទារឲ្យយើងត្រូវសិក្សាពីវាឲ្យបានលម្អិត ។ កន្លងមក សាធារណៈជនតែងតែគិតថា មិនមានការកំណត់អំពីទំហំនៃអត្រាការប្រាក់ទេ ទាំងធនាគារ ទាំងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ រួមទាំងការចងការឯកជនតែតាមពិតទៅរាល់គ្រប់ទម្រង់នៃការខ្ចី ដែលភ្ជាប់ជាមួយនឹងការប្រាក់ ត្រូវកំណត់អំពីទំហំនៃការយកអត្រាការប្រាក់ ។ យ៉ាងណាមិញ អត្រាការប្រាក់ដែល អនុវត្តក្នុងពេលបច្ចុប្បន្ន ត្រូវបានកំណត់ដោយបទដ្ឋានពីរផ្សេងគ្នា មួយជាអត្រាការប្រាក់ ដែលកំណត់ដោយធនាគារជាតិដែលអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ គ្រឹះស្ថាមីក្រូហិរញ្ញវត្ថុ និង ប្រតិបត្តិករជនបទ ហើយមួយទៀតនោះគឺ អត្រាការប្រាក់ដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សម្រាប់អនុវត្តចំពោះកិច្ចរដ្ឋប្បវេណីដូចជា ការខ្ចីមានការប្រាក់ ជាដើម ។

ជាមួយគ្នានេះកន្លងមក យើងសង្កេតឃើញមានបញ្ហាមួយដែលជាចម្ងល់ និង ជាចំណុចដែលមហាជនទូទៅ មានការលំបាកក្នុងការស្វែងយល់យ៉ាងខ្លាំង នោះគឺអត្រាការប្រាក់ដែលកំណត់សម្រាប់កិច្ចរដ្ឋប្បវេណី ក៏ព្រោះតែមានឯកសារច្បាប់ជាច្រើនដែលពាក់ព័ន្ធ ហើយឯកសារច្បាប់ទាំងនោះបានធ្វើការចង្អុលបង្ហាញ ការអនុវត្តបន្តបន្ទាប់គ្នា ដែលធ្វើឲ្យមានការលំបាកយ៉ាងខ្លាំងក្នុងការស្វែងយល់ ។ ក្នុងន័យនេះ សាធារណៈជនមួយចំនួនហាក់ដូចជាបាននឿយណាយក្នុងការស្វែង រកឯកសារតាមការចង្អុលបង្ហាញ ព្រោះតែមានច្រើនដំណាក់កាលពេក ច្បាប់នេះចង្អុលបង្ហាញឲ្យអនុវត្តច្បាប់នោះ ពេលរកឃើញច្បាប់នោះហើយ បែរជាមានការចង្អុលបង្ហាញទៀតឲ្យទៅមើលច្បាប់មួយផ្សេងទៀត ។

មួយជ្រុងទៀតនៃបញ្ហានោះគឺ ចង្វល់ទាក់ទងទៅនឹងមូលហេតុនៃការកំណត់អត្រាការប្រាក់ពីរផ្សេងគ្នារវាងកិច្ចរដ្ឋប្បវេណី និង កិច្ចការទាក់ទងនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ។ ការកំណត់អត្រាការប្រាក់ពីរផ្សេងគ្នានេះក៏ជាបញ្ហាមួយដ៏រសើបណាស់ដែរ ដែលគេតែងចោទសួរគ្នាថា ហេតុអ្វីបានជាតម្រូវឲ្យមាន ការកំណត់អត្រាការប្រាក់ជាពីរដូច្នេះ ? ជុំវិញរឿងការកំណត់អត្រាការប្រាក់នេះផងដែរ គន្លងមកយើងឃើញថាមាន ចម្ងល់ ការរិះគន់ និង ការផ្តល់ជាទស្សនជាច្រើនអំពីការកំណត់ពិដានអត្រាការប្រាក់ ដែលអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។ សាធារណៈជនមួយចំនួនយល់ថា ប្រកាសរបស់ធនាគារជាតិអំពី ការបើកទូលាយអំពីការកំណត់អត្រាការប្រាក់មានភាពល្អប្រសើរជាងប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ដោយសម្អាងទៅលើហេតុផលផ្សេងៗគ្នា។

ការលើកមកខាងលើនេះ សុទ្ធតែជាបញ្ហាដែលយើងតែងសង្កេតឃើញមាននៅក្នុងសង្គមយើងនាពេលបច្ចុប្បន្ន ហើយនេះក៏ជាបញ្ហាមួយដែលមិនមានឯកសារ ឬអ្នកជំនាញរូបណាចេញមុខមកធ្វើការបកស្រាយឲ្យបានលម្អិត និងពន្យល់ដល់សាធារណៈជនទូទៅ ដើម្បីបំបាត់នូវរាល់ចម្ងល់ដែលតែងតែកើតមាននាពេលកន្លងមកឡើយ ។

តាមរយៈស្នាដៃមួយនេះ រាល់ចម្ងល់ និង ភាពស្រពិចស្រពិលទាំងឡាយដែលតែងកើតមាននាពេលគន្លងមកជុំវិញបញ្ហាការប្រាក់នឹងអាចស្រាយបំភ្លឺបាន ។ ពិសេសជាងនេះទៅទៀតនោះស្នាដៃនេះនឹងក្លាយជាវិភាគទានមួយយ៉ាងមានសារៈសំខាន់ ក្នុងការជំរុញឲ្យសង្គមមានការអភិវឌ្ឍន៍សម្រេចបាននូវយុត្តិសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និង បញ្ចៀសបំណុលវ័ណ្ឌក ។

ជាមួយគ្នានេះ ចំពោះការស្រាវជ្រាវលើការប្រាក់នេះ យើងបានធ្វើការបែងចែកជា ៣ជំពូកធំៗ៖ ទី១ មូលដ្ឋាននៃការប្រាក់ ទី២ អត្រាការប្រាក់ដែលកំណត់ក្នុងកិច្ចរដ្ឋប្បវេណី និង ទី៣ អត្រាការប្រាក់ដែលកំណត់ដោយធនាគារជាតិអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

# ជំពូកទី១

# មូលដ្ឋាននៃការប្រាក់

# ជំពូកទី១

# មូលដ្ឋាននៃការប្រាក់

ផ្តើមចេញពីជំពូកនេះ យើងនឹងអាចស្វែងយល់អំពីនិយមន័យនៃការប្រាក់ ប្រភពនៃការប្រាក់ ប្រភេទនៃការប្រាក់ រួមនឹងនឹងចំណុចមួយចំនួនផ្សេងទៀត ដែលចំណុចទាំងនេះវាមានសារៈសំខាន់ក្នុងការផ្តល់ជាមូលដ្ឋានឲ្យយើងអាចមានភាពងាយស្រួល ក្នុងការស្វែងយល់ឲ្យបានស៊ីជម្រៅអំពីបញ្ហាការប្រាក់ ។

ជាមួយគ្នានេះ ដើម្បីជំរុញឲ្យការបកស្រាយមានភាពល្អប្រសើរ និង បានក្បោះក្បាយយើងបានធ្វើការបែកចែកជាពីរចំណុចធំៗ៖ ១.១ សញ្ញាណទូទៅស្តីពីការប្រាក់ និង ១.២ បទដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង ។

## ១.១ សញ្ញាណទូទៅស្តីពីការប្រាក់

ការប្រាក់វាមិនមែនជារឿងថ្មីទេ ដោយហេតុតែការប្រាក់នេះត្រូវបានគេយកទៅអនុវត្តក្នុងពេលអតីតកាលក្នុងជីវភាពប្រចាំថ្ងៃ ប៉ុន្តែការពីបុរាណកាលការប្រាក់ត្រូវបានគេទូទាត់ជាវត្ថុជាអាថ៌ដូចជា ស្រូវ អង្ករ បន្លែ ផ្លែឈើជាដើម ។ ដោយឡែកសម្រាប់ ក្នុងពេលបច្ចុប្បន្នវិញ ការប្រាក់ភាគច្រើនត្រូវបានគិតជាប្រាក់ មិនសូវមានការគិតជាវត្ថុផ្សេងទៀតនោះទេ ។

កាតព្វកិច្ចដែលបង់ជាការប្រាក់ជាធម្មតាអាចកើតឡើងក្រោមរូបភាពនៃការព្រមព្រៀងរបស់ភាគី ឬ ជួនកាលកើតឡើងក្រៅឆន្ទៈរបស់ភាគី ។ ទោះបីជាការប្រាក់ត្រូវកើតឡើងក្រោមទម្រង់ណាក៏ដោយ ភាគីដែលជាកូនបំណុលត្រូវមានកាតព្វកិច្ចក្នុងការបង់ការប្រាក់ជូនម្ចាស់បំណុល ។

### ១.១.១ និយមន័យនៃការប្រាក់

ការប្រាក់ សំដៅទៅលើចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀត ដែលត្រូវបានផ្តល់ទៅឲ្យតាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតម្លៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុដែលត្រូវបានប្រគល់ឲ្យអ្នកខ្ចី ហើយដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬ វត្ថុដែលបានខ្ចីមកគុណជាមួយនឹងអត្រាដែលត្រូវបានកំណត់ ។[1]វត្ថុដែលត្រូវបានប្រគល់ឲ្យអ្នកខ្ចីហៅថាប្រាក់ដើម ភាគដែលបានកំណត់ដែលត្រូវបានដាក់ទៅក្នុងចំនួនទឹកប្រាក់នៃប្រាក់ដើមហៅថា អត្រាការប្រាក់ ក្នុងន័យនេះការប្រាក់មិនមែនសំដៅតែប្រាក់តែម៉្យាងនោះទេ ពោលគឺការប្រាក់អាចជាវត្ថុផ្សេងទៀត

[1] កថាខណ្ឌទី១មាត្រា ៥៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ជាអាទិ៍ដូចជា ស្រូវ អង្ករ ជាដើម ដែលវាអាស្រ័យទៅលើកម្មវត្ថុនៃការព្រមព្រៀងរវាងគូភាគី ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគជាប្រាក់ នោះប្រាកដណាស់ថាកម្មវត្ថុនៃកិច្ចសន្យានោះគឺទឹកប្រាក់ ផ្ទុយទៅវិញប្រសិនបើកម្មវត្ថុ នៃកិច្ចសន្យាខ្ចីបរិភោគនោះជាវត្ថុផ្សេងវិញនោះ ការប្រាក់អាចជាប្រាក់ឬវត្ថុផ្សេងទៀត ។

**ឧទាហរណ៍៖** លោក **សុខ** បានខ្ចីប្រាក់ ១០០០ដុល្លារពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ខ** ។ នៅក្នុងកិច្ចសន្យាដែលធ្វើឡើងរវាងលោកជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានបញ្ជាក់ថាអត្រាការប្រាក់កំណត់ ១.៥% ក្នុងមួយខែ នៃប្រាក់ដែលបានខ្ចី ។ ដូចនេះលុយចំនួន ១០០០ដុល្លារ គឺជាប្រាក់ដើមរីឯចំនួន១.៥% គឺជា អត្រាការប្រាក់ ហើយ ការប្រាក់ = ១០០០ x ១.៥% = ១៥ដុល្លារ/ខែ ។

### ១.១.២ ប្រភពនៃការប្រាក់

ទូទៅការប្រាក់ អាចនឹងត្រូវកើតឡើងដោយសកម្មភាពផ្សេងៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ សកម្មភាពទាំងនោះជួនកើតឡើង ដោយមានការព្រមព្រៀងជួនកើតឡើងដោយគ្មានការព្រមព្រៀង ហើយសកម្មភាពទាំងនោះជួនកាលយើងមិនបានទាំងដឹងផងថាមានការប្រាក់ ។ និយាយជារួម ការប្រាក់ អាចកើតឡើងតាមឆន្ទៈ ឬ តាមការកំណត់របស់ច្បាប់ ។

សកម្មភាពដែលនាំឲ្យកើតមានការប្រាក់មួយចំនួន ភាគីមិនបានព្រមព្រៀងអំពីការកំណត់កាតព្វកិច្ចជាការប្រាក់នោះទេ ប៉ុន្តែច្បាប់បានកំណត់ទុកជាមុនថា សកម្មភាពនោះនឹងបង្កើតជាការប្រាក់ក្នុងករណីពិសេសណាមួយ ។ សកម្មភាពទាំងនោះមានជាអាទិ៍ដូចជា កិច្ចសន្យាទិញលក់ កិច្ចសន្យាអាណត្តិ សេចក្តីចម្រើនឥតហេតុ និង ការគ្រប់គ្រងដោយឈឺឆ្អាលជាដើម ។

ដោយឡែកចំពោះការប្រាក់ដែលមានប្រភពពីការព្រមព្រៀងវិញ នាពេលបច្ចុប្បន្នយើងឃើញត្រូវបានគេយកទៅអនុវត្តយ៉ាងសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច ។ យើងអាចឃើញជាក់ស្តែងគឺកិច្ចសន្យាខ្ចីបរិភោគ ដែលជាកិច្ចសន្យាមួយដែលកំពុងទទួលការពេញនិយមខ្លាំង ក្នុងស្រទាប់មហាជន ។

កិច្ចសន្យាខ្ចីបរិភោគ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកឲ្យខ្ចីមានករណីកិច្ចប្រគល់ការប្រើប្រាស់ដោយសេរី នូវប្រាក់ ស្បៀងអាហារ ស្រូវ ឬ វត្ថុជំនួស[2] ផ្សេងទៀតក្នុងអំឡុងពេលដែលមានកំណត់ឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកខ្ចី ហើយនៅក្រោយពេលដែលអំឡុង

[2] វត្ថុជំនួស សំដៅទៅលើវត្ថុដែលអាចត្រូវបានជំនួសដោយវត្ថុផ្សេងដែលមានប្រភេទ គុណភាព និង ចំនួនដូចគ្នា

ពេលនោះបានកន្លងផុត អ្នកខ្ចីមានករណីកិច្ចសងទៅឲ្យអ្នកឲ្យខ្ចីវិញ នូវវត្ថុដែលមានប្រភេទគុណភាព និង ចំនួនស្មើរគ្នានឹងវត្ថុដែលបានទទួលពីអ្នកឲ្យខ្ចីនោះ ។[3]

ក្នុងរឿងការខ្ចីបរិភោគនេះផងដែរ យើងតែងសង្កេតឃើញថា នៅពេលដែលកំឡុងពេលដែលបានកំណត់កន្លងផុតនោះ អ្នកខ្ចីមានកាតព្វកិច្ច ប្រគល់នូវប្រាក់ ឬ វត្ថុដែលមានប្រភេទ និង ចំនួនស្មើរគ្នានឹងកាលដែលអ្នកឲ្យខ្ចីបានប្រគល់ឲ្យកាលពីដំបូង ប៉ុន្តែប្រសិនជាភាគីបានការកំណត់អំពីការប្រាក់នៅក្នុងកិច្ចសន្យានោះ អ្នកខ្ចីត្រូវប្រគល់ទាំងការប្រាក់ដូចការកំណត់ក្នុង កិច្ចសន្យា ។ ក្នុងន័យនេះយើងអាចនិយាយបានថា ការខ្ចីបរិភោគត្រូវបានបែងចែកជាពីរគឺ ការខ្ចីបរិភោគដែលភ្ជាប់ជានឹងការប្រាក់ និងការខ្ចីបរិភោគដែលមិនមានភ្ជាប់នឹងការប្រាក់ ហើយក្នុងពេលបច្ចុប្បន្ននេះ ការខ្ចីបរិភោគដែលភ្ជាប់ជាមួយការប្រាក់ គឺជាវិធីដ៏សំខាន់មួយ សម្រាប់សកម្មភាពសេដ្ឋកិច្ច ។

យ៉ាងណាមិញពេលនេះ យើងនឹងលើកយកកិច្ចសន្យាខ្ចីបរិភោគដែលភ្ជាប់ជាការប្រាក់មកធ្វើការបង្ហាញខ្លះៗ ។

ជាទូទៅកិច្ចសន្យាខ្ចីបរិភោគត្រូវបង្កើតឡើង ដោយការព្រមព្រៀងរវាងអ្នកឲ្យខ្ចី និង អ្នកខ្ចីតែប៉ុណ្ណោះ ។[4]

នៅក្នុងការបង្កើតកិច្ចសន្យាខ្ចីបរិភោគនេះ ប្រទេសនីមួយៗ បានធ្វើការកំណត់លក្ខខណ្ឌក្នុងការបង្កើតផ្សេងៗគ្នា នៅក្នុងប្រទេសខ្លះកិច្ចសន្យាខ្ចីបរិភោគ បង្កើតអានុភាពនៅពេលដែលមានការប្រគល់វត្ថុ ដូចនេះលក្ខខណ្ឌចាំបាច់ក្នុងការបង្កើតកិច្ចសន្យាខ្ចីបរិភោគគឺ ការប្រគល់វត្ថុ បើគ្មានការប្រគល់វត្ថុ ក៏កិច្ចសន្យានេះគ្មានអានុភាពដែរ ។ ក៏ប៉ុន្តែការអនុវត្តនៅកម្ពុជាយើង គឺមិនអនុវត្តដូចនេះទេ កិច្ចសន្យាខ្ចីបរិភោគ ត្រូវបង្កើតឡើងដោយការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ មិនចាំបាច់តម្រូវឲ្យប្រគល់វត្ថុនោះទេ ហើយវត្ថុ ឬ ប្រាក់ ទាំងនោះអាចប្រគល់នៅពេលអនាគតក៏បាន ។

ជាគោលការណ៍ ដើម្បីគោរពគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា ភាគីអាចកំណត់នៅក្នុងកិច្ចសន្យាថា អានុភាពនៃកិច្ចសន្យានឹងកើតឡើង នៅពេលដែលធ្វើលិខិតកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ឬ នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យានោះបាន ។

[3] មាត្រា ៥៧៨ នេះត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីដោយបន្ថែមពាក្យ « ស្រូវ »នៅបន្ទាប់ពាក្យ «ស្បៀង»

[4] មាត្រា ៥៧៩នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដោយឡែកកិច្ចសន្យាខ្ចីបរិភោគនេះ ភាគីក៏អាចភ្ជាប់ជាមួយការប្រាក់ផងដែរ ។ តែក្នុងករណីនេះ ភាគីត្រូវតែមានការសរសេរជាលាយលក្ខខណ្ឌអក្សរ និង មានចុះហត្ថលេខាពីសំណាក់អ្នកខ្ចី បើមិនដូច្នោះទេ សិទ្ធិលើបំណុលដែលជាការប្រាក់នឹងគ្មានអានុភាពនោះទេ ។ ការបង្កើតលក្ខខណ្ឌនេះ គឺដើម្បីជួយសម្រាលបន្ទុកដ៏ធ្ងន់ធ្ងររបស់កូនបំណុលចំពោះការសងប្រាក់ដើម និងការប្រាក់ ។ ប៉ុន្តែក្នុងជីវភាពប្រចាំថ្ងៃ អាចមានការសន្យាបង់ការប្រាក់ដោយផ្ទាល់មាត់ ។ ក្នុងករណីនេះដើម្បីការពារកុំឲ្យមានវិវាទដែលអ្នកខ្ចី ទាមទារឲ្យសងវិញនូវការប្រាក់ដែលខ្លួនបានបង់ដោយស្ម័គ្រចិត្តរួចហើយ ទើបក្រមរដ្ឋប្បវេណីមាត្រា៥៨៣ ត្រង់កថាខណ្ឌទី៤បានកំណត់យ៉ាងច្បាស់ចំពោះករណីនេះ ។ កថាខណ្ឌនេះចែងថា « *នៅក្នុងការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ដោយមិនយោងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដែលមានចុះហត្ថលេខារបស់អ្នកខ្ចី ប្រសិនបើអ្នកខ្ចីបានសង ដោយដឹងថា សិទ្ធិលើបំណុលដែលជាការប្រាក់នឹងមិនកើតមានឡើងឡើយ ប្រសិនបើមិនបានធ្វើជា លាយល័ក្ខណ៍អក្សរ និង ចុះហត្ថលេខាពីអ្នកខ្ចី នោះការសងមានអានុភាពត្រឹមកម្រិតដែលបានសងនោះតែប៉ុណ្ណោះ* » ។

## ១.២ បទដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង

បទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និងកំណត់អត្រាការប្រាក់ជាប្រធានបទមួយយ៉ាងសំខាន់ដែលយើងមិនអាចមើលរំលងបាន ។ សម្រាប់ពេលបច្ចុប្បន្ននេះយើងឃើញថា មានមនុស្សច្រើនណាស់ដែលមិនបានដឹងថា ការកំណត់អត្រាការប្រាក់ដែលអនុវត្តសម្រាប់ពេលបច្ចុប្បន្នត្រូវកំណត់ដោយដោយច្បាប់ណាមួយ ព្រោះដោយហេតុថាមានការបែងចែងបទដ្ឋានគតិយុត្តិជាពីរផ្សេងគ្នា សម្រាប់ធ្វើការកំណត់អំពីការប្រាក់ ហើយបទដ្ឋានគតិយុត្តិទាំងនោះហាក់ដូចជាមានភាព រប៉ាតរប៉ាយ ដែលធ្វើឲ្យអ្នកច្បាប់ រួមនឹងសាធារណៈជនពិបាកក្នុងការស្វែងយល់ ។

ចំពោះការអនុវត្តសព្វថ្ងៃ អត្រាការប្រាក់ត្រូវកំណត់ជាពីរផ្សេងគ្នា ពោលគឺអត្រាការប្រាក់ដែលអនុវត្តសម្រាប់ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករជនបទ ដែលត្រូវកំណត់ដោយធនាគារជាតិ ហើយអត្រាការប្រាក់ផ្សេងទៀត ដែលអនុវត្តចំពោះកិច្ចរដ្ឋប្បវេណី ត្រូវកំណត់ដោយក្រមរដ្ឋប្បវេណី និង ច្បាប់ដោយឡែកផ្សេងទៀត ។

### ១.២.១ បរិបទនៃការចែកការគ្រប់គ្រង

កត្តាដែលនាំឲ្យមានច្បាប់ពីរផ្សេងគ្នា គ្រប់គ្រងចំពោះការកំណត់អត្រាការប្រាក់ ដែលអនុវត្តនាពេលបច្ចុប្បន្ន គឺដោយហេតុថា ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថិតនៅក្រោមការគ្រប់គ្រង

ដោយច្បាប់ដោយឡែក ។ ដូចនេះរាល់ការកំណត់អត្រាការប្រាក់ គួរណាតែឋិតក្រោមកំណត់ដោយច្បាប់ពិសេសទាំងអស់នោះពោលគឺ មិនអាចអនុវត្តតាមអត្រាការប្រាក់ ដែលបានកំណត់ដោយក្រមរដ្ឋប្បវេណីនោះទេ ។

យោងតាមមាត្រា ៣៣ នៃច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃធនាគារជាតិកម្ពុជា ចែងថា « *ធនាគារកណ្តាល ( ធនាគារជាតិនៃកម្ពុជា ) ត្រូវទទួលខុសត្រូវផ្តាច់មុខក្នុងការផ្តល់ ឬ ដកហូតអាជ្ញាប័ណ្ណ និង ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និង គ្រឹះស្ថានឯទៀតដោយចេញប្រកាស បទបញ្ជា និង ការណែនាំផ្សេងៗព្រមទាំងចាត់វិធានការចាំបាច់ ដើម្បីធ្វើឲ្យ សម្រេចមុខងារដោយអនុវត្តបទដ្ឋាននៃការផ្តល់ ឬដកហូតអាជ្ញាប័ណ្ណ និង ត្រួតពិនិត្យព្រមទាំងមធ្យោបាយសមស្រប* »។ មាត្រានេះ សរបង្ហាញ ឲ្យយើងឃើញយ៉ាងច្បាស់ថា ធនាគារជាតិនៃកម្ពុជាជាស្ថាប័នតែមួយគត់ដែលមាន សម្តកិច្ចក្នុងការចេញប្រកាស បទបញ្ជា និង សេចក្តីណែនាំដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យ សកម្មភាពរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។ មួយជ្រុងនៃមូលហេតុដែលអាចឲ្យយើងយកមកគិតពិចារណាផងដែរនោះគឺ កម្ពុជាប្រកាន់យកការអនុវត្តទីផ្សារសេរី ដែលទាមទារឲ្យមានការប្រកួតប្រជែងគ្នារវាងគ្រឹះស្ថានហិរញ្ញវត្ថុដែលកំពុងប្រតិបត្តិការនៅកម្ពុជា ។ ក្នុងន័យនេះ គ្រប់គ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ត្រូវរិះរកគ្រប់មធ្យោបាយធ្វើយ៉ាងណា ដើម្បីទាក់ទាញអតិថិជនតាមរយៈការបង្កើនប្រសិទ្ធភាពប្រតិបត្តិការ និង កាត់បន្ថយហានិភ័យ ឬ ធ្វើយ៉ាងណាឲ្យការផ្តល់សេវាកម្មល្អប្រសើរ និង អត្រាការប្រាក់ទាបជាងគេ ជាដើម ។ កត្តាទាំងនេះហើយ ដែលជាមូលហេតុក្នុងការកំណត់សមត្ថកិច្ច អោយធនាគារជាតិជាអ្នកកំណត់អំពីចំនួនអត្រាការប្រាក់ អនុវត្តទៅលើគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ១.២.២ បទដ្ឋានគតិយុត្តិគ្រប់គ្រងចំពោះកិច្ចរដ្ឋប្បវេណី

ការខ្ចីប្រាក់ តែងកើតមានឡើងដោយជៀសមិនរួចឡើយក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ហើយការខ្ចីប្រាក់នេះ ត្រូវបានអនុវត្តយ៉ាងសកម្ម សម្រាប់មនុស្សទូទៅក្នុងពេលបច្ចុប្បន្ននេះ ។ ទោះបីជាការខ្ចីប្រាក់ ត្រូវបានអនុវត្តយ៉ាងញឹកញាប់យ៉ាងណាក៏ដោយ ក៏នៅតែមានមនុស្សច្រើនណាស់ដែលមិនទាន់បានដឹងអំពីអត្រាការប្រាក់ ដែលត្រូវកំណត់ឲ្យអនុវត្តចំពោះការខ្ចីប្រាក់ទាំងនោះ ថាតើត្រូវកំណត់ដោយច្បាប់ណានោះទេ ? ប្រសិនបើយើងលើកអំពីបញ្ហាអត្រាការប្រាក់ក្នុងរឿងកិច្ចរដ្ឋប្បវេណីមកនិយាយវាហាក់ដូចជាមានភាពស្មុគស្មាញបន្តិច ព្រោះមានលិខិតបទដ្ឋានជាច្រើនដែលកំណត់

អំពីបញ្ហានេះ ។ មូលដ្ឋានគ្រឹះ ដែលកំណត់អត្រាការប្រាក់ក្នុងកិច្ចរដ្ឋប្បវេណី គឺផ្តើមចេញពីក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ហើយក្រមរដ្ឋប្បវេណីដែលអនុវត្តនាពេលបច្ចុប្បន្ន យើងឃើញមានមាត្រាមួយចំនួនដែលបានចែងអំពីការប្រាក់ ។ ក្រមរដ្ឋប្បវេណី បានពន្លិចឲ្យយើងឃើញអំពីការបែងចែក ការប្រាក់ ដែលត្រូវបានកំណត់ជាពីរផ្សេងគ្នា ទី១ ការប្រាក់ដែលកំណត់ដោយច្បាប់ដែលបានកម្រិតអំពីអត្រាការប្រាក់ច្បាស់លាស់ និង ទី២ ការប្រាក់ដែលកំណត់តាមការព្រមព្រៀង ក្នុងនោះ ក្រមរដ្ឋប្បវេណីកម្ពុជា មិនបានកំណត់ជាក់លាក់ ពីកម្រិតអត្រាការប្រាក់នោះទេ ។ រហូតដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ទើបច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានប្រកាសឲ្យប្រើដោយ ព្រះមហាក្សត្រ ។ ក្នុងច្បាប់នេះ យើងឃើញមាត្រា១៧ បានចែងអំពីការកម្រិតអត្រាការប្រាក់ តាមការព្រមព្រៀង ក៏ប៉ុន្តែមាត្រានេះក៏មិនបានកំណត់ឲ្យច្បាស់លាស់អំពីកម្រិតនៃអត្រាការប្រាក់នោះទេ ដោយទុកចន្លោះមួយក្នុងការអនុវត្ត និង ធ្វើការចង្អុលបង្ហាញឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអ្នកកំណត់បន្ត។

ជាចុងក្រោយនៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១១ ស្របពេលនឹងកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានដាក់ចុះនូវប្រកាសលេខ១២៨ កយ.ប្រក/១១ស្តីពីអាត្រាការប្រាក់ដែលត្រូវបានកម្រិត ។ ចាប់ពីពេលនោះហើយ ដែលការប្រាក់តាមការព្រមព្រៀងក្នុងកិច្ចរដ្ឋប្បវេណីត្រូវបានកម្រិត យ៉ាងជាក់លាក់រហូតមកដល់បច្ចុប្បន្ន ។

### ១.២.៣ បទដ្ឋានគតិយុត្តិគ្រប់គ្រងចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

បច្ចុប្បន្ន គ្រឹះស្ថានហិរញ្ញវត្ថុ ដូចជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ប្រតិបត្តិករជនបទ ដែលកំពុងប្រតិបត្តិការ នៅប្រទេសកម្ពុជាមានច្រើន ដោយសារតែភាពរីកចម្រើនលូតលាស់នៃគ្រឹះស្ថានហិរញ្ញវត្ថុទាំងនោះ បានកើនឡើងគួរកត់សំគាល់ ពីមួយថ្ងៃទៅមួយថ្ងៃ ។

ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ប្រតិបត្តិករជនបទទាំងអស់ ដែលឋិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តតាមវិធានដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា រួមទាំងការកំណត់អត្រាការប្រាក់ផងដែរ ។ គួររំលឹកផងដែរថានៅមុនពេលមានការដាក់ចុះនូវប្រកាស លេខ ធ៧-០១៧-១០៩ ប្រ.ក ស្តីពីការដាក់ពិដានអាត្រាការប្រាក់ឥណទាន ការកំណត់ការប្រាក់ដែលត្រូវអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ត្រូវអនុឡោមតាមការប្រកាសលេខ ធ៧.០៩.២១៣ ប្រ.ក ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ។

### ១.២.៤ អន្តរកាលក្នុងការគ្រប់គ្រង

ក្រមរដ្ឋប្បវេណី គឺជាវិធាននៃនីតិឯកជនរួម ។ មានន័យថា ទំនាក់ទំនងឯកជនគេត្រូវអនុវត្ត តាមវិធាននៃក្រមរដ្ឋប្បវេណី ប៉ុន្តែគេនឹងអនុវត្តតាមច្បាប់ពិសេសចំពោះសកម្មភាពអ្វីមួយ ប្រសិនបើ មានចែងក្នុងច្បាប់ពិសេសនោះ ។ ម៉្យាងទៀតប្រសិនបើមានច្បាប់ពិសេសដែរ តែមិនមានបញ្ញត្តិ ចែង ឬចែងមិនច្បាស់លាស់ នោះក្រមរដ្ឋប្បវេណីនឹងត្រូវយកទៅអនុវត្ត ។ តួយ៉ាងដូចជា គ្រឹះស្ថាន ធនាគារ និង ហិរញ្ញវត្ថុឋិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជាក៏ពិតមែន តែចំពោះ សកម្មភាពមួយចំនួន ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីក្នុងករណីដែលធនាគារជាតិ នៃកម្ពុជាមិនបាន កំណត់ ។ យ៉ាងណាមិញ ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ អត្រាការប្រាក់ដែលកំណត់ក្នុងកិច្ចសន្យានេះ ត្រូវអនុវត្តតាមប្រកាសដែលចេញ ដោយធនាគារជាតិនៃកម្ពុជា តែចំពោះនីតិវិធីក្នុងការបង្កើតកិច្ចសន្យា សុពលភាព ការរំលាយ ជាដើមត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីវិញ ។

# ជំពូកទី២
# ការប្រាក់កំណត់នៅក្នុង
# កិច្ចរដ្ឋប្បវេណី

# ជំពូកទី២

# ការប្រាក់កំណត់នៅក្នុងកិច្ចរដ្ឋប្បវេណី

ដូចបានលើកឡើងខាងលើ ការប្រាក់ដែលកំណត់ចំពោះកិច្ចរដ្ឋប្បវេណី វាហាក់ដូចជាមានលក្ខណៈស្មុគស្មាញបន្តិច ក្នុងការស្វែងយល់ ព្រោះមានការកំណត់ដោយលិខិតបទដ្ឋានផ្សេងៗជាច្រើន ដែលទាមទារឲ្យយើងត្រូវសិក្សាដោយចំណាយពេលច្រើនបន្តិច ។

ក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ការចង់ការប្រាក់ឯកជន ត្រូវបានធ្វើប្រតិបត្តិការយ៉ាងសកម្ម ។ ប្រជាពលរដ្ឋជាច្រើនបានជ្រើសរើសយកការចង់ការប្រាក់ឯកជន ទោះពួកគាត់ដឹងថាគាត់ត្រូវមានបន្ទុកយ៉ាងធ្ងន់ធ្ងរ ក្នុងការបង់ការប្រាក់ជូនដល់ម្ចាស់បំណុលក៏ដោយចុះ ។ ដើមចមដែលនាំឲ្យប្រជាពលរដ្ឋ នៅតែជ្រើសរើសយកការប្រើប្រាស់ សេវាខ្ចីប្រាក់ឯកជន ដោយសារតែភាពខ្វះខាត ភាពងាយស្រួលមិនស្មុគស្មាញចំពោះលិខិតស្នាមផ្សេងៗ មានភាពឆាប់រហ័ស និងលាក់ការសម្ងាត់បានល្អ ( ដឹងតែរវាងម្ចាស់បំណុល និង កូនបំណុលប៉ុណ្ណោះ ) ។ ចំនុចទាំងអស់នេះហើយដែលជំរុញឲ្យការចងការប្រាក់ឯកជន នៅតែមានសក្តានុពល បើទោះបីជាការយកអត្រាការប្រាក់នោះខ្ពស់ជាងអត្រាការប្រាក់ ដែលកំណត់ដោយច្បាប់ក៏ដោយ ។

ផ្តើមចេញពី ក្រមរដ្ឋប្បវេណីដែលជានីតិរូមនៃនីតិឯកជន ឃើញថាការប្រាក់ត្រូវបានបែងចែកជាពីរ គឺការប្រាក់តាមកិច្ចសន្យា និង ការប្រាក់តាមការកំណត់របស់ច្បាប់ ។

ហេតុដូចនេះក្នុងជំពូកនេះ យើងមានគោលបំណងធ្វើការបកស្រាយ ទៅលើពីរចំណុចធំៗ គឺ ការប្រាក់ដែលកំណត់ដោយច្បាប់ ( ១.១ ) និង ការប្រាក់តាមកិច្ចសន្យា ( ១.២ )

## ១.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

### ១.១.១ អត្ថន័យទូទៅនៃអត្រាការប្រាក់ដែលកំណត់ដោយច្បាប់

ប្រសិនបើ គូរភាគីបានព្រមព្រៀងកំណត់អំពីចំនួនអត្រាការប្រាក់ គេនឹងអនុវត្តតាមការព្រមព្រៀងនោះ ។ ផ្ទុយទៅវិញ នៅពេលដែលភាគីមិនបានកំណត់អំពីចំនួននៃអត្រាការប្រាក់ទេ ចំនួននៃអត្រាការប្រាក់ ត្រូវអនុវត្តតាមបញ្ញត្តនៃច្បាប់។ ការប្រាក់ប្រភេទនេះ គេហៅថាការប្រាក់កំណត់ដោយច្បាប់។

នៅបណ្តាលប្រទេសមួយចំនួន ជំនួសឲ្យអាត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដែលមិនប្រែប្រួល គេយកអាត្រាការប្រាក់ផ្លូវការកំណត់ដោយធនាគារជាតិមកធ្វើការប្រាក់ដែលកំណត់ដោយច្បាប់ ។[5]

ដោយសារសេចក្តីសម្រេចថា តើត្រូវអនុវត្តអត្រាការប្រាក់ ដែលអាចប្រែប្រួលបាននេះ មិនត្រឹមតែតម្រូវអោយ មានការពិចារណាផ្នែកច្បាប់ប៉ុណ្ណោះទេ **តែត្រូវគិតផ្នែកសេដ្ឋកិច្ច និង នយោបាយ** ថែមទៀត ដែលនេះ ជាវិធីសាស្ត្របែបទំនៀមទម្លាប់នៃការកំណត់ អត្រាការប្រាក់ដែលមិនប្រែប្រួល ត្រូវបានយកមកប្រើនៅក្នុង ក្រមរដ្ឋប្បវេណីកម្ពុជានេះ[6] ។

## ១.១.២ ប្រភេទផ្សេងៗនៃអត្រាការប្រាក់ដែលកំណត់ដោយច្បាប់

តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៩ សង្កេតឃើញថា ការប្រាក់មានពីរ ប្រភេទគឺៈ ការប្រាក់ធម្មតា និង ការប្រាក់សមាស ។

ការប្រាក់ធម្មតា ជាការប្រាក់ដែលច្បាប់កំណត់ជាទូទៅ ហើយជាគោលការណ៍ការប្រាក់ធម្មតាកំណត់ដោយច្បាប់នេះ ត្រូវបានអនុវត្តលើគ្រប់ស្ថានភាពទាំងអស់ លើកលែងតែគូរភាគីបានព្រមព្រៀងគ្នាកំណត់ជាមុននូវចំនួនអត្រាការប្រាក់ផ្សេងពីននេះ ។ ត្រង់ចំនុចនេះក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់យ៉ាងច្បាស់ថា ចំពោះកាតព្វកិច្ចដែលត្រូវបង្កើតការប្រាក់ក្នុងករណីដែលគ្មានការកំណត់ផ្សេងទេ ត្រូវគិតអត្រាការប្រាក់ចំនួន៥ភាគរយ( ប្រាំភាគរយ )ក្នុងមួយឆ្នាំ[7]។ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ត្រូវបានអនុវត្តចំពោះករណីដែលកាតព្វកិច្ច ដែលភ្ជាប់នឹងការប្រាក់តាមច្បាប់ ឬ តាមកិច្ចសន្យា លើកលែងតែមានការព្រមព្រៀងពីអាត្រាផ្សេងពីនេះ ។[8]

ការប្រាក់សមាសក៏ត្រូវបានកំណត់ នៅក្នុងក្រមរដ្ឋប្បវេណីផងដែរត្រង់មាត្រា ៣១៩ ដែលមានខ្លឹមសារថា នៅក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពីមួយឆ្នាំឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានធ្វើការដាស់តឿនឲ្យសងយ៉ាងណាក៏ដោយក៏កូនបំណុលមិនព្រមសងប្រាក់នោះ ម្ចាស់បំណុលអាចបូកបញ្ចូលការប្រាក់យឺតយាវ ឬ ខកខាន

[5] មាត្រា ៣១៨ កថាខណ្ឌទី ៣នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី
[6] មាត្រា ៣១៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី
[7] មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី
[8] មាត្រា ៣១៨ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

ទៅក្នុងប្រាក់ដើមបាន ។[9] ការប្រាក់ដែលត្រូវបានគិតលើចំនួនប្រាក់ដើមថ្មីដែលកើតឡើងពីការបូកបញ្ចូលរវាងការប្រាក់យឺតយ៉ាវ និង ប្រាក់ដើម ហៅថាការប្រាក់សមាស ។[10] **ឧទាហរណ៍៖** ក្នុងករណីដែលប្រាក់បានខ្ចីមានចំនួន១០០០ដុល្លារ ដោយគិតអត្រាការប្រាក់៨% ក្នុងមួយឆ្នាំ ។ ក្នុងករណីនេះ ប្រសិនបើ កូនបំណុលបានខកខានក្នុងការបង់ការប្រាក់ជូនម្ចាស់បំណុលពេញមួយឆ្នាំ បើទោះបីជាមានការដាស់តឿន ពីម្ចាស់បំណុលយ៉ាងណាក៏ដោយ នោះម្ចាស់បំណុលអាចធ្វើការបូកបញ្ចូលការប្រាក់ ៨% ជាមួយប្រាក់ដើម ១០០០ដុល្លារ ។ ដូចនេះ ការប្រាក់សមាស គឺជាការប្រាក់ដែលគិតលើប្រាក់ដើមថ្មីគឺ១០៨០ដុល្លារ ។ ដោយសារតែការប្រាក់សមាសជាបន្ទុកបន្ថែមចំពោះកូនបំណុល (អ្នកខ្ចីប្រាក់)ការប្រាក់សមាសនេះអាចធ្វើបាន លុះត្រាតែបំពេញតាមលក្ខខណ្ឌតាមច្បាប់កំណត់ ។

សូមចងចាំថា ការប្រាក់សមាសអាចអនុញ្ញាតអោយយកបាន តែក្នុងករណីកូនបំណុលខានសងការប្រាក់ចាប់ពីមួយឆ្នាំឡើងទៅតែប៉ុណ្ណោះ ។ ចំពោះករណីដែលយើងតែងតែបានជួបប្រទះក្នុងការអនុវត្តប្រចាំថ្ងៃនោះ គឺការកំណត់អត្រាការប្រាក់ប្រចាំខែ និងបញ្ចូលការប្រាក់នោះជា ប្រាក់ដើម ហើយមួយខែក្រោយកូនបំណុលមិនសងប្រាក់ត្រូវតែហាមឃាត់តាមមាត្រា៣១៩ នៃក្រមរដ្ឋប្បវេណីនេះ។ ហេតុដូច្នេះ ទោះបីជាមានការព្រមព្រៀងរវាងភាគីក៏ដោយការព្រមព្រៀងនេះគ្មានសុពលភាពនោះទេ[11] ។

ចំពោះកាតព្វកិច្ចដែលមាន គោលបំណងសងជាប្រាក់ ទោះបីជាកូនបំណុលមានសំអាងបញ្ជាក់ថា ការយឺតយ៉ាវក្នុងការសងបានកើតឡើងដោយប្រធានសក្តិក៏ដោយ ក៏កូនបំណុលនោះមិនអាចរួចផុតពីការសងការប្រាក់ ក្នុងអំឡុងពេលនៃការយឺតយ៉ាវនោះបានដែរ ។ ត្រង់ចំនុចនេះ សូមទាញចំណាប់អារម្មណ៍ថា ការយឺតយ៉ាវក្នុងការសងការប្រាក់ ច្បាប់បានបញ្ញត្តិអំពីស្ថានភាពពីរផ្សេងគ្នាគឺ៖

ការយឺតយ៉ាវ ក្នុងការសងការប្រាក់ ដោយគ្មានកំហុសរបស់កូនបំណុល ។ ប្រសិនបើចំពោះកាតព្វកិច្ចជាប្រាក់ ដែលកូនបំណុលមិនមានលទ្ធភាពក្នុងការអនុវត្តឡើយ ។ ក្នុងករណីនៃអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចផ្សេងទៀតក្រៅពីកាតព្វកិច្ចជាប្រាក់ ប្រសិនបើកូនបំណុលមានកំហុសនោះ

[9] មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី

[10] មាត្រា ៣១៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

[11] មាត្រា ៣១៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

កាតព្វកិច្ចដំបូងនឹងក្លាយទៅជា កាតព្វកិច្ចនៃសំណងការខូចខាត ។ ផ្ទុយទៅវិញ បើកាតព្វកិច្ចជាប្រាក់ នោះកាតព្វកិច្ចដំបូង មិនត្រូវរលត់ដោយអលទ្ធភាពក្នុងការអនុវត្តទេ ។ រាល់ករណីដែលកូនបំណុលមិនអាចសងចំពោះកាតព្វកិច្ចជាប្រាក់ គឺជាការយឺតយ៉ាវក្នុងការអនុវត្ត ហើយម្ចាស់បំណុលអាចទាមទារសំណងការខូចខាតបាន ។ សរុបសេចក្តីមក ការកន្លងហួសនៃពេលកំណត់អនុវត្តកាតព្វកិច្ចជាប្រាក់ត្រូវក្លាយជាការយឺតយ៉ាវក្នុងការអនុវត្តជានិច្ច ហើយការប្រាក់នៅក្នុងអំឡុងពេលយឺតយ៉ាវដែលជាសំណងនៃការខូចខាត ត្រូវបានទទួលស្គាល់ ដោយមិនគិតពិចារណានត្តិភាព ឬអនត្តិភាពនៃកំហុសកូនបំណុលនោះទេ ។

<u>**ឧទាហរណ៍៖**</u> សំណងការខូចខាតដែលមានចំនួនលើសពីការប្រាក់ ក្នុងអំឡុងពេលនៃការយឺតយ៉ាវ គឺករណីដែលអ្នកឲ្យខ្ចី ( ម្ចាស់បំណុល ) បានពន្យល់ទៅអ្នកខ្ចី (កូនបំណុល) ថា អ្នកខ្ចីនឹងជួបប្រទះការលំបាក ប្រសិនបើ ខ្លួនមិនបានទទួលប្រាក់កម្ចីនោះតាមពេលកំណត់ ពីព្រោះខ្លួនត្រូវប្រើប្រាស់ប្រាក់កម្ចីនេះ ដើម្បីបង់ថ្លៃតាមកិច្ចសន្យាទិញលក់ ឲ្យទៅតតីយជន ប៉ុន្តែកូនបំណុលនោះមិនបាន អនុវត្តកាតាព្វកិច្ចតាមពេលកំណត់ ( ពេលកំណត់បានកន្លងហួស ) ដូច្នេះហើយតតិយជនរំលាយកិច្ចសន្យា ធ្វើអោយអ្នកឲ្យខ្ចីទទួលការខូចខាត ។ ចំពោះការខូចខាតដែលកើតឡើង ដោយស្ថានភាពពិសេសរបស់ម្ចាស់បំណុល ប្រសិនបើកូនបំណុលមានកំហុស ការខូចខាតនោះអាចក្លាយទៅជាកម្មវត្ថុនៃសំណងនៃការខូចខាត[12] ។

## ១.២ អត្រាការប្រាក់ដែលកំណត់តាមកិច្ចសន្យា

បន្ទាប់ពីយើងបានដឹងអំពីការប្រាក់កំណត់ដោយច្បាប់រួចមក យើងនឹងបន្តសិក្សាអំពីការប្រាក់ដែលកំណត់ក្នុងកិច្ចសន្យា ។ ដោយអនុឡោមតាម មាត្រា៣ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ ចែងអំពីគោលការណ៍គ្រឹះនៃការគោរពឆន្ទៈរបស់បុគ្គលឯជនដែលហៅថា « **គោលការណ៍ស្វ័យភាពនៃ-បុគ្គលឯកជន** » ដែលបានកំណត់ថាក្រមនេះគោរពនូវសេរីភាពនៃឆន្ទៈបុគ្គល និង បញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តិប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ ក្នុងន័យនេះ សង្គមបច្ចុប្បន្ន បុគ្គលគ្រប់រូប មានសេរីភាព និង សមភាព ក្នុងការបង្ហាញឆន្ទៈលើសិទ្ធិរបស់ខ្លួន ។ ដូចនេះ បុគ្គលគ្រប់រូប មិនត្រូវបានចងដោយឆន្ទៈរបស់បុគ្គលដ៏ទៃនោះទេ លើកលែងតែ មានការព្រមព្រៀងក្នុងការជួញដូរតាមកិច្ចសន្យាជាមួយបុគ្គលដ៏ទៃនោះ ដោយឆន្ទៈរបស់

[12]មាត្រា ៣៩៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

ខ្លួន ។ គោលការណ៍នេះ ត្រូវចែងជាគោលការណ៍មូលដ្ឋានក្នុងក្រមរដ្ឋប្បវេណីដូចជា សេរីភាពនៃលក្ខណៈបុគ្គលតាមច្បាប់ សេរីភាពក្នុងការប្រើប្រាស់អាស្រ័យផល និង ចាត់ចែងទ្រព្យ និងសេរីភាពក្នុងកិច្ចសន្យា ។ ដូច្នេះការកំណត់ចំពោះអត្រាការប្រាក់នេះ ភាគីអាចមានសេរីភាពក្នុងការព្រមព្រៀងគ្នា ដើម្បីកំណត់ការប្រាក់ដែលច្បាប់ធ្វើការទទួលស្គាល់តាមការកម្រិត ។

### ១.២.១ និយមន័យនៃអត្រាការប្រាក់ក្នុងកិច្ចសន្យា

ជាគោលការណ៍ អាត្រាការប្រាក់ដែលត្រូវកំណត់តាមការព្រមព្រៀងរបស់ភាគី អត្រាការប្រាក់នេះ ហៅថា « **អត្រាការប្រាក់ក្នុងកិច្ចសន្យា** »[13] ។ តាមបញ្ញត្តិនៃមាត្រា ៥៨៤ ក្នុងករណីដែលត្រូវបង់ការប្រាក់ តាមការព្រមព្រៀងរបស់ភាគី ឬ បញ្ញត្តិច្បាប់ ប្រសិនបើភាគីបើពុំបានកំណត់អត្រាការប្រាក់ទេនោះត្រូវអនុលោមតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់[14]។ ន័យជារួមយើងអាចយល់បានថា ក្នុងករណីដែលភាគីបានព្រមព្រៀងគ្នា សន្យាបង់ការប្រាក់ តែមិនបានកំណត់នូវអត្រាការប្រាក់នេះទេ ត្រូវយកអត្រាការប្រាក់ដែលបានកំណត់ក្នុងក្រមនេះ គឺអត្រាការប្រាក់ដែលកំណត់ក្នុងច្បាប់[15] ។ ការកំណត់អត្រាការប្រាក់ក្នុងកិច្ចសន្យាមាន ២ ករណី៖

<u>**ករណីទី១៖**</u> ការព្រមព្រៀងកំណត់ចំនួនអត្រាការប្រាក់ ដែលមានកម្រិតខ្ពស់ជាងអត្រាការប្រាក់កំណត់ដោយច្បាប់ ។ ចំពោះអត្រាការប្រាក់នៅក្នុងកិច្ចសន្យា ដែលខ្ពស់ជាងអត្រាការប្រាក់កំណត់ដោយច្បាប់ ត្រូវកំណត់ក្នុងទម្រង់ជាលាយល័ក្ខអក្សរ ដោយហត្ថលេខារបស់គូភាគី ទើបមានអនុភាព[16] ។

<u>**ករណីទី២៖**</u> ការព្រមពៀងកំណត់អត្រាការប្រាក់ ទាបជាងអត្រាដែលកំណត់ដោយច្បាប់។ ខ្ពស់ជាងកិច្ចសន្យា ក្នុងករណីនេះ បើអត្រាការប្រាក់ដែលបានព្រមគ្នានោះទាបជាងការប្រាក់ដែលកំណត់កំណត់ដោយច្បាប់ នោះការព្រមព្រៀងនោះនឹងមានសុពលភាពក្នុងអនុវត្ត ទោះបីជាការព្រមព្រៀងនោះធ្វើជាលាយល័ក្ខអក្សរ ចុះហត្ថលេខាកូនបំណុល ឬ ផ្ទាល់មាត់ក៏ដោយ ។

---

[13] មាត្រា ៥៨៤ វាក្យខណ្ឌ១នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

[14] មាត្រា ៥៨៤ កថាខណ្ឌ១នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[15] មាត្រា ៥៨៤ វាក្យខណ្ឌ២នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

[16] មាត្រា ៥៨៤ កថាខ័ណ្ឌ២ វាក្យខណ្ឌ១នៃសេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

យើងបានដឹងច្បាស់ហើយអំពី ការកំណត់អត្រាការប្រាក់តាមកិច្ចសន្យា អំពីមូលដ្ឋាននានា នីតិវិធីក្នុងគិតការប្រាក់តាមកិច្ចសន្យានេះ ។ នៅមានចំណុចសំខាន់មួយទៀតនៃ ការកំណត់អត្រាការប្រាក់តាមការព្រមព្រៀងនេះ គឺ **ការប្រាក់ដែលត្រូវបានកម្រិត ។**

ដោយយោងតាមបញ្ញត្តិត្រងមាត្រា៥៨៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់និយមន័យថា អត្រាការប្រាក់ដែលត្រូវបានកម្រិត សំដៅទៅលើអត្រាការប្រាក់អតិបរមា ដែលអាចកំណត់បាន។ ដោយស្រេមច្បាប់ និង តាមការព្រមព្រៀងរបស់ភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តិ។

បើទោះបីជា ភាគីអាចកំណត់ការប្រាក់ ខ្ពស់ជាងអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ខាងលើនេះបាន ក៏ប៉ុន្តែភាគីមិនអាចកំណត់អត្រានេះលើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិតនេះឡើយ ។[17] ប្រសិនបើភាគីបានកំណត់អត្រាការប្រាក់លើសពី អត្រាការប្រាក់ដែលត្រូវបានកម្រិត ភាគដែលលើសពី កម្រិតនៃអត្រាការប្រាក់កម្រិតដោយច្បាប់នោះ ត្រូវចាត់ទុកជាមោឃៈ រីឯអ្នកខ្ចីមានករណីកិច្ចសង តែចំពោះការប្រាក់ដែលត្រូវបានគណនាតាមអត្រាការប្រាក់ ដែលត្រូវបានកម្រិតនោះប៉ុណ្ណោះ ។

នៅក្នុងរណី ដែលបានសងការប្រាក់ដែលលើសពីអត្រាការប្រាក់ ដែលត្រូវបានកម្រិតហើយ ត្រូវចាត់ទុកថាភាគដែលលើសពីកម្រិតនោះ ជាការកាត់បំណុលទៅលើប្រាក់ដើម ។ នៅក្នុងករណីដែលបានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកម្រិតហើយ តែនៅមានសេសសល់ទៀត អ្នកឲ្យខ្ចីត្រូវសងទៅឲ្យអ្នកខ្ចី ដោយភ្ជាប់ជាមួយប្រាក់សំណងនៃការខូចខាតដោយគណនាតាមអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីថ្ងៃដែលបានបង្កើតឲ្យមានការសេសសល់នៃការសងរហូតដល់ថ្ងៃដែលបានសងនោះ ។[18]

យោងតាមមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី អត្រាការប្រាក់ដែលត្រូវបានកម្រិត ដែលកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ៥៨៥ (ការប្រាក់កម្រិត) នៃក្រមរដ្ឋប្បវេណី ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រឹមអត្រាចាប់ពី ១០ % ភាគរយ ទៅ ៣០% ក្នុងមួយឆ្នាំ ។ ដូចនេះផ្អែកតាមបញ្ញត្តិនេះ យើងដឹងបានត្រឹមតែចន្លោះ នៃអត្រាការប្រាក់ដែលត្រូវបាន

[17] មាត្រា ៥៨៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] មាត្រា ៥៨៥ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

កម្រិតប៉ុណ្ណោះ ដូច្នេះ ដើម្បីដឹងលម្អិតពីទំហំជាក់លាក់នៃអត្រាការប្រាក់ដែលត្រូវបានកម្រិតនេះ គឺត្រូវមើលក្នុងប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ។

ផ្អែមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធមិលេខ ១២៨.កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ក្នុងប្រការ១ ការប្រាក់ដែលត្រូវបានកម្រិតត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១៨% ក្នុងមួយឆ្នាំ។

ការប្រាក់នៅក្នុងកិច្ចរដ្ឋប្បវេណីនេះ ត្រូវបានបែងចែកចេញជា ៣ ប្រភេទគឺ ការប្រាក់ធម្មតាដែលត្រូវបានកម្រិត ការប្រាក់យឺតយ៉ាវ ការប្រាក់បង្គរ ឬ ការប្រាក់សមាស ។

### ១.២.៣ ប្រភេទនៃអត្រាការប្រាក់តាមកិច្ចសន្យា

#### ១.២.៣.១ អត្រាការប្រាក់ធម្មតាដែលត្រូវបានកម្រិត

ក្រមរដ្ឋប្បវេណី តែងតែគោរពនូវស្វ័យភាពនៃបុគ្គលឯកជនជានិច្ច ។ មានន័យថា គូភាគីដែលជាបុគ្គលឯកជន អាចធ្វើការព្រមព្រៀងដោយសេរី រួមទាំងការកំណត់នូវការចំនួននៃអត្រាការប្រាក់ផងដែរ ។ ប៉ុន្តែ ចំពោះបញ្ហាការប្រាក់នេះ ប្រសិនបើយើងបើកទូលាយឲ្យបុគ្គលឯកជនអាចកំណត់ដោយសេរី ដោយឥតដែនកំណត់នោះ វានឹងមានបញ្ហាក្នុងសង្គមដូចជា ម្ចាស់បំណុលរំលោភស្ថានភាពលើកូនបំណុល ដើម្បីទទួលបានកម្ចីកូនបំណុលសុខចិត្តឲ្យអត្រាការប្រាក់ខ្ពស់ហួសហេតុ ជាដើម ។ ហេតុផលនេះហើយ ទើបក្រមរដ្ឋប្បវេណីបានកម្រិតទៅលើការព្រមព្រៀងរបស់គូភាគី ក្នុងការកំណត់អំពីចំនួនអត្រាការប្រាក់ ។ នេះគេហៅថា ការប្រាក់ដែលត្រូវបានកម្រិត។

ការប្រាក់ដែលត្រូវបានកម្រិតនេះ មានចែងក្នុងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណី ។ ប៉ុន្តែមិនឃើញមានកំណត់អំពីចំនួននៃអាត្រាការប្រាក់ដែលត្រូវបានកម្រិតឡើយ ។ រហូតដល់ច្បាប់ស្តីការអនុវត្តក្រមរដ្ឋប្បវេណី ក៏មិនទាន់មានកំណត់ច្បាស់លាស់អំពីការប្រាក់ដែលត្រូវបានកម្រិតឡើយ ដោយគ្រាន់តែបានចង្អុលបង្ហាញឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចេញនូវប្រកាសដើម្បីកំណត់ចំនួនការប្រាក់ដែលត្រូវបានកម្រិត ក្នុងចន្លោះពី ១០ ភាគរយ ដល់ ៣០ ភាគរយ ។[19] មានន័យថាក្រសួងយុត្តិធមិត្រូវកំណត់ចំនួននៃអត្រាការប្រាក់ដែលត្រូវបានកម្រិតមិនឲ្យតិចជាង ១០ ភាគរយ និងមិនឲ្យលើសពី៣០ ភាគរយឡើយ ។

[19] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១ មាត្រា១៧ កថាខណ្ឌ១

ប្រកាសលេខ ១២៨ កយ ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត បានកំណត់យ៉ាងជាក់លាក់ អំពីចំនួនអត្រាដែលត្រូវបានកម្រិត តាមអត្ថន័យនៃប្រកាសនេះ គូរភាគីអាចធ្វើការព្រមព្រៀង ដោយកំណត់ចំនួននៃអត្រាការប្រាក់បាន ប៉ុន្តែមិនឲ្យលើសពី ១៨ (ដប់ប្រាំបី) ភាគរយក្នុងមួយឆ្នាំឡើយ[20] ។

### ១.២.២.២ អត្រាការប្រាក់យឺតយ៉ាវ

នៅពេលពេល ភាគីកូនបំណុលមិនបានអនុវត្តន៍កាតព្វកិច្ច តាមពេលកំណត់សង នោះ ហើយជាស្ថានភាពយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។[21] ក្នុងស្ថានភាពយឺតយ៉ាវនេះ ម្ចាស់បំណុល អាចទាមទារសំណងការខូចខាត ដែលកើតចេញពីការយឺតយ៉ាវនោះ តាមផ្លូវតុលាការ ។ ហើយ តុលាការនឹងវិនិច្ឆ័យដោយឆន្ទានុសិទ្ធិក្នុងផ្តល់សំណងការខូចខាត តាមការជាក់ស្តែង ។ ប៉ុន្តែ ប្រសិនបើគូរភាគីបានព្រមព្រៀងជាមុន កំណត់ចំនួននៃការខូចខាត នោះតុលាការនឹងវិនិច្ឆ័យផ្តល់ សំណងការខូចខាតនោះ តាមការព្រមព្រៀងរបស់គូរភាគី ។ នៅក្នុងបញ្ហាការប្រាក់ ការកំណត់ ទុកជាមុននូវសំណងបែបនេះ គេហៅថា **ការប្រាក់យឺតយ៉ាវ** ។

ដូចគ្នានឹងអត្រាការប្រាក់ដែលត្រូវបានកម្រិតដែរ ការប្រាក់យឺតយ៉ាវត្រូវបាន ច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី ចង្អុលបង្ហាញឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញនូវប្រកាសដើម្បីកំណត់ ចំនួនការប្រាក់យឺតយ៉ាវ ក្នុងទំហំពី១,២ ទៅ ២ដងនៃអត្រាការប្រាក់ដែលត្រូវបានកម្រិត ។[22] មាន ន័យថា ក្រសួងយុត្តិធម៌ត្រូវកំណត់ចំនួននៃអត្រាការប្រាក់ដែលត្រូវបានកម្រិត មិនឲ្យតិចជាង១០ភាគរយ និង មិនឲ្យលើសពី៣០ ភាគរយឡើយ ។

យោងតាមប្រការ២ នៃប្រកាសលេខ ១២៨ កយ ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ គូរភាគីអាចកំណត់ទុកជាមុននូវអត្រា ការប្រាក់យឺតយ៉ាវមិនឲ្យលើសពី ១,៥ ដងនៃការប្រាក់ដែលត្រូវបានកម្រិតឡើយ ។ មានន័យថា អត្រាការប្រាក់យឺតយ៉ាវ វាមានមានលក្ខណៈប្រែប្រួលទៅតាមអត្រាការប្រាក់ដែលត្រូវបានកម្រិត ។

---

[20] ប្រការ១ កថាខណ្ឌទី១នៃប្រកាសលេខ ១២៨ កយ ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១របស់ក្រសួង យុត្តិធម៌

[21] បទបង្ហាញអំពីកិច្ចសន្យាខ្ចីបរិភោគរបស់មេធាវី អ៊ី ប៉ូលី ទូរស្សន៍បាយ៉ន ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦

[22] ច្បាប់ស្តីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ មាត្រា១៧ កថាខណ្ឌទី២ និងទី៣

**ឧបមាថា៖** គូរភាគីបានបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដោយភ្ជាប់ជាមួយនូវអត្រាការប្រាក់ ១២ ភាគរយ ក្នុងមួយឆ្នាំ ។ ករណីនេះ ប្រសិនបើភាគីនៃកិច្ចសន្យាបានព្រមព្រៀងកំណត់ ជាមុននូវអត្រាការប្រាក់យឺតយ៉ាវនោះភាគីអាចកំណត់បានមិនឲ្យលើពី១៨ភាគរយក្នុងមួយឆ្នាំឡើយ ។ ព្រោះ១,៥ ដង នៃ១២ ភាគរយ ស្មើនឹង ១៨ ភាគរយ ។

### ១.២.២.៣ ការប្រាក់បង្គរ ឬ ការប្រាក់សមាស

ក្នុងករណីដែលមានការយឺតយ៉ាវមិនបានសងការប្រាក់ សម្រាប់រយៈពេលចាប់ពីមួយឆ្នាំឡើងទៅ ហើយទោះបីជាម្ចាស់បំណុលបានដាស់តឿន អោយសងយ៉ាងណាក៏ដោយ ក៏កូនបំណុលមិនព្រមសងការប្រាក់នោះ ម្ចាស់បំណុលអាចបូកបញ្ចូល ការប្រាក់ដែលយឺតយ៉ាវនោះ ទៅក្នុងប្រាក់ដើមបាន ។[23] ការបូកបញ្ចូលការប្រាក់ទៅក្នុងប្រាក់ដើមបែបនេះតាមច្បាប់ហៅថា ការប្រាក់សមាស ។[24]

អនុលោមតាមមាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណី ដើម្បីអាចគិតការប្រាក់ សមាស ឬ ការប្រាក់បង្គរបាន ត្រូវមានលក្ខខណ្ឌ ២៖

- កូនបំណុលយឺតយ៉ាវក្នុងការសងការប្រាក់រយៈពេលមួយឆ្នាំពេញ
- ម្ចាស់បំណុលដាស់តឿនយ៉ាងណាក៏កូនបំណុលមិនព្រមសងការប្រាក់នោះ

ដរាបណាលក្ខខណ្ឌទាំង២នេះ ត្រូវបានបំពេញ ទើបម្ចាស់បំណុលអាចគិតការប្រាក់សមាសនេះបាន ។

**ឧទាហរណ៍៖** លោក **ខ** បានខ្ចីប្រាក់លោក **គ** ចំនួន ១០០០០មុឺនដុល្លារ ដោយសន្យាគ្នាគិតការប្រាក់ ១០% ក្នុងមួយឆ្នាំ ។ ក្រោយមក **ខ** មិនបានបងការប្រាក់រយៈពេលមួយឆ្នាំពេញ ។ ដូចនេះ **គ** អាចបូក ការប្រាក់ដែលយឺតយ៉ាវ ១០% ក្នុងមួយឆ្នាំដែលស្មើនឹង ១០០០ ដុល្លារ ទៅក្នុងប្រាក់ដើមបាន ។ ដូចនេះប្រាក់ដើមគឺ ១១០០០ ដុល្លារ ហើយ **គ** ចាប់គិតការប្រាក់លើប្រាក់ដើមថ្មី ១១០០០ ដុល្លារ ។

## ១.៣ ពេលវេលា និង ទីកន្លែងនៃការបង់ការប្រាក់

### ១.៣.១ ពេលវេលា

ជាគោលការណ៍ ប្រសិនបើភាគីបានកំណត់កាលបរិច្ឆេទនៃការសង ម្ចាស់បំណុលមិនអាចទាមទារឲ្យកូនបំណុលសងមុនកាលកំណត់បានឡើយបានឡើយ ។ ពោល គឺម្ចាស់បំណុលត្រូវរង់

[23] មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[24] មាត្រា ៣១៩ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

ចាំរហូតដល់ពេលកំណត់សងបានមកដល់ ទើបម្ចាស់បំណុលអាចទាមទារឲ្យកូនបំណុលបាន ។ ចំណែកឯកូនបំណុលវិញ មិនចាំបាច់សងដល់ម្ចាស់បំណុលទេ ប្រសិនបើកាលបរិច្ឆេទនៃការសង មិនទាន់មកដល់ ។ ប៉ុន្តែកូនបំណុលអាចសងទៅម្ចាស់បំណុលបាន ទោះបីជាកាលកំណត់មិនទាន់មកដល់ក៏ដោយ ។ ការសងមុនកំណត់ពេលរបស់កូនបំណុលបែបនេះ គេហៅថា **ការបោះបង់ផលប្រយោជន៍នៃការកំណត់ពេល**[25]។

បើតាមក្រមរដ្ឋប្បវេណីកម្ពុជាមាត្រា ៥៩៤ កថាខណ្ឌទី២ ចែងថា "ប្រសិនបើ ភាគីមិនបានកំណត់កាលបរច្ឆេទនៃការសងទេ អ្នកអោយខ្ចីអាចដាស់តឿនឲ្យសង ក្នុងអំឡុងពេលសមរម្យបាន ។ ក្នុងន័យនេះអ្នកឲ្យខ្ចី ឫម្ចាស់បំណុល ត្រូវធ្វើការដាស់តឿន ហើយកំណត់រយៈពេលសមរម្យទៅអោយកូនបំណុលដើម្បីអនុវត្តការតាព្វកិច្ច ក្នុងរណីដែលគូរភាគីទាំងពីរមិនបានកំណត់កាលបរិច្ឆេទនៃការសង ហើយកូនបំណុលត្រូវអនុវត្តកាតាព្វកិច្ច នៅកាលបរិច្ឆេទនៃការកំណត់សមរម្យដោយម្ចាស់បំណុលមកដល់។ កូនបំណុលត្រូវសងតាមខ្លឹមសារនៃការតាព្វកិច្ច និងតាមគោលការណ៍នៃភាពសុចរិត នឹងភាពស្មោះត្រង់[26] ។ កូនបំណុលត្រូវសងនៅម៉ោងធម្មតាតាមទំនៀមទំលាប់ និងគោលការណ៍សុចរិតភាព និងភាពស្មោះត្រង់ ។ កូនបំណុលអាចយកវត្ថុជំនួសផ្សេងទៀតក្រៅពីវត្ថុជាកម្មវត្ថុក្នុងកិច្ចសន្យា ដើម្បីធ្វើការសងទៅម្ចាស់បំណុលបាន ក្នុងករណីម្ចាស់បំណុលព្រមទទួលយក។ អ្នកខ្ចីនៃកិច្ចសន្យាបរិភោគដោយគ្មានការប្រាក់ អាចសងនៅពេលណាក៏បានផ្ទុយទៅវិញ បើអ្នកខ្ចីបរិភោគដែលមានភ្ជាប់ការប្រាក់ អាចសងនៅមុនកាលបរិច្ឆេទសង ដែលបានកំណត់ក្នុងកិច្ចសន្យាបាន ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលធ្វើឲ្យមានការខូចខាតដល់អ្នកអោយខ្ចីដោយសារការសងនោះ អ្នកខ្ចីត្រូវសងសំណងនៃការខូចខាត ដោយផ្អែកតាមស្មារតីនៃមាត្រា ៣៣០កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ។

ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ការសងមុនពេលកំណត់ និង ធ្វើអោយខូចផលប្រយោជន៍ដល់ការទទួលការប្រាក់របស់អ្នកឲ្យខ្ចី ហេតុនេះហើយបានជាមានចម្ងល់មួយកើតឡើងថា ប្រហែលជាអ្នកខ្ចីគ្មានសេរីភាព ក្នុងការបោះបង់ចោលនូវផលប្រយោជន៍នៃការកំណត់ពេលនេះទេ ហេតុដូច្នេះតាមបញ្ញត្តិ៥៩៤ កថាខ័ណ្ឌ៤ បានអនុញ្ញាតអោយអ្នកខ្ចីអាចបោះបង់ចោល

[25] មាត្រា ៥៩៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

26 មាត្រា ៩៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

នូវផលប្រយោជន៍នៃការកំណត់អំឡុងពេលបាន ។ តែអ្នកខ្ចីមានករណីកិច្ចសង់ការខូចខាត់របស់អ្នកអោយខ្ចី ។

### ១.៣.២ ទីកន្លែងនៃការសងការប្រាក់

ដោយយោងតាមមាត្រា ៥៩៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៩ បានចែងថា ប្រសិនពុំមានការព្រមព្រៀងរវាងភាគី អំពីទីកន្លែងនៃការសងទេ អ្នកខ្ចីត្រូវយកវត្ថុនៃដែលជាកម្មវត្ថុនៃការសងនោះ ទៅសង នៅលំនៅឋានរបស់អ្នកឲ្យខ្ចី ។ តាមខ្លឹមសារនេះ ដោយផ្អែកតាមគោលការណ៍ទូទៅនៃច្បាប់កាតព្វកិច្ច ទីកន្លែងនៃការសង គឺលំនៅដ្ឋានរបស់ម្ចាស់បំណុល ។[27] ក៏ប៉ុន្តែភាគី អាចធ្វើការព្រមព្រៀងគ្នាក្នុងការកំណត់ទីកន្លែងសងប្រាក់នេះ នៅក្នុងកិច្ចសន្យាបាន ។ សោហ៊ុយនៃការសងនេះជាបន្ទុករបស់កូនបំណុល ក៏ប៉ុន្តែបើសើហ៊ុយនៃការសងនោះកើនឡើងដោយសារការផ្លាសប្តូរ ទីលំនៅរបស់ម្ចាស់បំណុល ម្ចាស់បំណុលត្រូវទទួលបន្ទុកនូវចំនួនកំណើននៃសោហ៊ុយនោះ[28] ។

[27] មាត្រា ៥៩៥ កថាខណ្ឌ១ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី

[28] មាត្រា ៥៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី៣

# អត្រាការប្រាក់ដែលកំណត់

# ដោយធនាគារជាតិ

# អនុវត្តសម្រាប់

# គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

# ជំពូកទី៣

# អត្រាការប្រាក់ដែលកំណត់ដោយធនាគារជាតិអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

សេវាកម្មឥណទាន គឺជាសេវាមួយដែលកំពុងតែមានការរីកចម្រើនខ្លាំង នាពេលបច្ចុប្បន្ន ។ ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តករជនបទ បានបន្តបង្កើតថ្មី និង ពង្រីកវិសាលភាពឥណទានរបស់ខ្លួនជាហូរហែរ ។ ប្រជាពលរដ្ឋចាប់តាំងពីទីក្រុងដល់ទីជនបទ បានខ្ចីបំណុលពីធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ការខ្ចីប្រាក់ទាំងនោះមានគ្រប់ទំហំទាំង កម្ចីខ្នាតតូច ខ្នាតមធ្យម និង ខ្នាតធំ ។

ប្រជាពលរដ្ឋដែលប្រើប្រាស់សេវាឥណទានទាំងនោះមួយចំនួន មិនបានដឹងទេថា សព្វថ្ងៃធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលគាត់បានទៅខ្ចីប្រាក់ទាំងនោះ បានធ្វើការកំណត់អត្រាការប្រាក់ដោយ ធនាគារ និង មីក្រូហិរញ្ញវត្ថុទាំងនោះ ។

គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុទាំងអស់ ដែលកំពុងប្រតិបត្តិការឥណទាននៅក្នុងប្រទេសកម្ពុជា ត្រូវឋិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិ ។ បច្ចុប្បន្នមានច្បាប់ជាច្រើនដែលត្រូវបង្កើតឡើង ដើម្បីរៀបចំ និង គ្រប់គ្រងទៅលើគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមានជាអាទិ៍ដូចជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ច្បាប់ស្តីភតិសន្យាហិរញ្ញវត្ថុ ច្បាប់ស្តីពី លក្ខខណ្ឌសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ជាដើម ។

បញ្ហាដែលសាធារណៈជនទូទៅ កំពុងតែមានការចាប់អារម្មណ៍ខ្លាំង ក្នុងមួយរយៈពេលចុងក្រោយនោះគឺ ប្រកាសរបស់ធនាគារជាតិស្តីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន ។ នៅមុនពេលមានការដាក់ចុះនូវប្រកាសនេះ អត្រាការប្រាក់ឥណទានត្រូវកំណត់ ដោយប្រកាសស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ។

ហេតុដូច្នេះដើម្បីជំរុញឲ្យការបកស្រាយមានភាពងាយស្រួល និង បានក្បោះក្បាយយើងបានធ្វើការបែងចែកជាពីរចំណុចធំ១៖ ១.១ អត្រាការប្រាក់ដែលកំណត់មុនប្រកាសស្តីពីការដាក់ពិដានអត្រាការប្រាក់ ១.២ ការដាក់ពិដានអត្រាការប្រាក់ឥណទាន ។

## ១.១ អត្រាការប្រាក់ដែលអនុវត្តមុនប្រកាសស្តីពីការដាក់ពិដានអត្រាការប្រាក់

នៅមុនពេលដែលមានការដាក់ចុះនូវ ប្រកាសស្តីពី ការដាក់ពិដានអត្រាការឥណទាននៅថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៧ អត្រាការប្រាក់ឥណទានដែលត្រូវអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ គឺត្រូវអនុទ្បោមតាម ប្រកាសលេខ ធ៧-០៩-២១៣ ប្រ.ក ស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ។ ប្រកាសទាំងពីរនេះ វាមានលក្ខណៈខុសពីគ្នាស្រឡះដោយប្រកាសស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ បានផ្តល់ឱកាសយ៉ាងពេញលេញ ដល់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ អាចធ្វើការកំណត់អត្រាការប្រាក់ឥណទាន បានដោយសេរី ប៉ុន្តែប្រកាសថ្មីស្តីពី ការកំណត់ពិដានអត្រាការប្រាក់ឥណទាន បានធ្វើការកម្រិតអត្រាការប្រាក់អតិបរមាដែលគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុអាចយកពីអតិថិជនរបស់ខ្លួន ។

### ១.១.១ ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

ប្រកាសស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ បានចេញឲ្យប្រើនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៩ ដោយធនាគារជាតិនៃកម្ពុជា ។ ប្រការ១ នៃប្រកាសនេះ ចែងថា « *គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀល និង ជារូបិយប័ណ្ណបរទេស យោងតាមលទ្ធភាព និង គោលនយោបាយ អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុនីមួយៗ* » ។ មានន័យថាប្រកាសនេះ មិនបានធ្វើការកំណត់អត្រាការប្រាក់ឥណទាននោះទេ ដោយទុកឱកាសឲ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុទាំងនោះ ជាអ្នកធ្វើការកំណត់អត្រាការដោយខ្លួនឯងតាមដែលអាចធ្វើទៅបានដើម្បីទាក់ទាញអថិតិជន ។ ក៏ប៉ុន្តែ នៅរៀងរាល់ដំណាច់ខែនីមួយៗ គ្រប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុត្រូវរាយការណ៍ជាលាយ លក្ខណ៍អក្សរ ស្តីពីអត្រាការប្រាក់ជាមធ្យមដែលអនុវត្តលើការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា ។[29] នេះលក្ខខណ្ឌមួយ ដែលធ្វើឲ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ មិនអាចកំណត់អត្រាការប្រាក់ឥណទានកម្រិតខ្ពស់ហួសហេតុពេកទោះគ្រឹះស្ថានទាំងនោះ មានសិទ្ធិក្នុងការកំណត់អត្រាការប្រាក់បានដោយសេរីក៏ដោយ តែត្រូវឋិតក្រោមការតាមដាន ត្រួតពិនិត្យរបស់ធនាគារជាតនៃកម្ពុជា ដូច្នេះអត្រាការប្រាក់ឥណទានត្រូវឋិតក្រោមកម្រិតមួយសមរម្យ ។

ហេតុផលមួយជាក់លាក់ ដែលនាំឲ្យធនាគារជាតិ មិនធ្វើការកំណត់អត្រាការប្រាក់ឥណទានព្រោះដោយសារតែ ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន បានប្រកាន់យកការអនុវត្តរបបទីផ្សារសេរី

[29] ប្រការ២ នៃប្រកាសស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ឆ្នាំ ២០០៩

ដូច្នោះហើយ ប្រសិនបើធនាគារជាតិលូកដៃ ក្នុងការកំណត់អត្រាការប្រាក់ សម្រាប់ប្រតិបត្តិការឥណទាននោះមានន័យថា រដ្ឋបានលូកដៃចូល ឬ អន្តរាគមន៍ ក្នុងវិស័យឯកជន ដែលវាជាសកម្មភាពផ្ទុយស្រឡះពីគោលការណ៍គ្រឹះ នៃរបបទីផ្សារសេរីដែលបើកឱកាស យ៉ាងពេញលេញដល់វិស័យឯកជន ធ្វើប្រកួតប្រជែង ផលិតទំនិញ ឬ សេវា និង កំណត់តម្លៃក៏ដូចជាកំណត់អត្រាការប្រាក់ដោយឯករាជ្យ មិនមានការចូលអន្តរាគមន៍នោះទេ ។ ម៉្យាងវិញទៀត ផ្អែកលើអ្នកជំនាញ និង របាយការណ៍មួយចំនួនយើងឃើញអត្រាការសម្រាប់ពេលនោះវាទាប ហេតុដូច្នេះមិនមានលក្ខខណ្ឌណាដែលតម្រូវឲ្យធនាគារជាតិចូលអន្តរាគមន៍ចំពោះការប្រាក់ឥណទាននោះទេ ។

### ១.១.២ មូលដ្ឋានក្នុងការកំណត់អត្រាការប្រាក់

ដូចបានជម្រាបជូនខាងលើមកហើយ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានសេរីភាពក្នុងការកំណត់អត្រាការប្រាក់ ។ ដើម្បីកំណត់អំពីអត្រាការប្រាក់ គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុមានមូលដ្ឋានមួយចំនួនដូចជា ប្រភពទុន តម្លៃប្រតិបត្តិការ កម្រិតហានិភ័យ និងស្ថានភាពទីផ្សារ ជាដើម ។

#### ១.១.២.១ ប្រភពទុន

ទុន ជាប្រភពដ៏សំខាន់ក្នុងការជំរុញឲ្យគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ មានដំណើរការ ។ ជាទូទៅ ទុនមានប្រភពច្រើនដែលក្នុងនោះរួមមាន ដើមទុនរបស់ម្ចាស់ហ៊ុន ប្រាក់សន្សំរបស់អតិថិជន និងទុនពីក្រៅប្រទេស ។ កាលណាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានប្រភពទុនផ្សេងគ្នា ការកំណត់អំពីអត្រាការប្រាក់ក៏មានចំនួនខុសគ្នាដែរ ព្រោះប្រភពទុនជាមូលហេតុចម្បង ដែលនាំឲ្យមានការកំណត់អត្រាការប្រាក់ឥណទាន ។ កន្លងមក យើងសង្កេតឃើញថាចំពោះធនាគារ ការកំណត់អត្រាការប្រាក់ឥណទានហាក់ដូចជា មានលក្ខណៈអត្រាតិចជាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រោះដោយហេតុថា ធនាគាទទួលបានទុនច្រើនមកពីប្រាក់សន្សំរបស់អតិថិជន ដែលប្រាក់សន្សំទាំងនោះ ជាប្រភពទុនដែលមានការចំណាយតិច ។ ដោយឡែកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុវិញ ទុនចម្បងគឺទុនពីក្រៅប្រទេស ដូចជាកម្ចីធនាគារបរទេសជាដើម ។ ជាទូទៅ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបង់ការប្រាក់ នៅពេលដែលធ្វើកម្ចីពីធនាគារបរទេស។ ដូចនេះដើម្បីទទួលបានប្រាក់ចំណេញ គ្រឹះស្ថានហិរញ្ញវត្ថុត្រូវបូកបន្ថែមទៅលើអត្រាការប្រាក់នោះ ។

និយាយជារួម ទុនដែលមានការចំណាយទាបការប្រាក់ក៏ទាប ទុនដែលមានការចំណាយខ្ពស់អត្រាការប្រាក់ក៏ខ្ពស់ ។

### ១.១.២.២ តម្លៃប្រតិបត្តិការ

ជាការពិតណាស់ តម្លៃប្រតិបត្តិការតែងកើតមានគ្រប់ពេល ហើយការចំណាយទៅលើប្រតិបត្តិការអាចមានការប្រែប្រួលទៅតាមប្រភេទនៃផលិតផលឥណទាន[30] ។ ផលិតផលឥណទានខ្លះមានការចំណាយទៅលើប្រតិបត្តិការតិចដូចនេះអត្រាការក៏មានកម្រិតទាបដែរ ក៏ប៉ុន្តែផលិតផលឥណទានខ្លះ មានការចំណាយប្រតិបត្តិការខ្ពស់ នោះការកំណត់អត្រាការប្រាក់ក៏មានកម្រិតខ្ពស់ផងដែរ ។ ក្នុងន័យនេះ យើងឃើញថាគ្រឹះស្ថានមួយចំនួន បានផ្តល់ជម្រើសដល់អតិថិជនរបស់ខ្លួនក្នុងការសម្រេចចិត្តថា ត្រូវបង់ប្រាក់ត្រឡប់មកគ្រឹះស្ថានវិញដល់ការិយាល័យ ឬ តម្រូវឲ្យបុគ្គលិករបស់គ្រឹះស្ថានទៅទទួលប្រាក់បង់ប្រចាំខែដល់ទីលំនៅរបស់គាត់ ក្រោយពេលទទួលបានកម្ចី ។ ប្រសិនបើអតិថិជនជ្រើសរើស ការបង់ប្រាក់ដល់ការិយាល័យនោះ អត្រាការប្រាក់នឹងមានកម្រិតទាប ជាងការបង់ប្រាក់នៅទីលំនៅរបស់អតិថិជន នេះដោយសារតែការបង់ប្រាក់នៅទីលំនៅរបស់អតិថិជន មានការចំណាយផ្សេងៗទៅលើប្រតិបត្តិការខ្ពស់ជាង ការបង់នៅតាមការិយាល័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ យើងអាចឃើញជាក់ស្តែង ការបង់ប្រាក់នៅទីលំនៅរបស់អតិថិជនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវចំណាយលើសម្ភារៈ ( ម៉ូតូ សាំង... ) និង ពេលវេលា ជាដើម ។

### ១.១.២.៣ កម្រិតហានិភ័យ

ហានិភ័យ សំដៅលើកម្រិតអសុវត្ថិភាពនៃឥណទាន ។ ជាការពិតណាស់ កម្រិតហានិភ័យនៃឥណទានមិនមានលក្ខណៈដូចគ្នានោះទេ វាមានការប្រែប្រួលទៅតាមប្រភេទនៃឥណទាន ។ ប្រភេទឥណទានខ្លះដែលមានកម្រិតហានិភ័យខ្ពស់ អត្រាការប្រាក់ មានកម្រិតខ្ពស់ ចំនែកឯឥណទានខ្លះដែលមានកម្រិតហានិភ័យទាប ការប្រាក់ក៏មានកម្រិតទាបដែរ ។ យើងសង្កេតឃើញជាទូទៅកម្ចី ដែលមិនតម្រូវឲ្យមានការដាក់ទ្រព្យធានា ការប្រាក់ត្រូវបានកំណត់ខ្ពស់ជាងកម្ចី ដែលមានការដាក់ទ្រព្យធានា ដោយហេតុថា កម្ចីគ្មានទ្រព្យធានា មានហានិភ័យខ្លាំងជាងកម្ចីធំដែលមានការដាក់ទ្រព្យធានា ។ ម្យ៉ាងវិញទៀត នៅក្នុងការអនុវត្តសព្វថ្ងៃនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការបង់ប្រាក់កម្ចីជូនគ្រឹះស្ថានពីសំណាក់អតិថិជនមានបីប្រភេទគឺ ទី១ កម្ចីបង់ប្រាក់ដើមរំលស់ថេរ និង ការប្រាក់រៀងរាល់ខែ ទី២ កម្ចីបង់ប្រាក់ដើម និង ការប្រាក់រំលស់ថេរ និងទី៣ កម្ចីបង់ប្រាក់ដើមចុងវគ្គ និងការប្រាក់រៀងរាល់ខែ ។ ជាធម្មតាកម្ចីប្រភេទទី១ និងទី២ ការប្រាក់មានកម្រិតទាបជាង កម្ចីប្រភេទទី៣ ព្រោះកម្ចីប្រភេទទី៣មានកម្រិតហានិភ័យខ្ពស់ ក្នុងករណី

---

[30] ផលិតផលឥណទាន សំដៅលើប្រភេទកម្ចីដែលគ្រឹះស្ថានធនាគារ ឬហិរញ្ញវត្ថុបានផ្តល់ជូនអតិថិជន ជាអាចីដូចជាកម្ចីក្រុម កម្ចីឯកត្តជនជាដើម ។

អតិថិជនមានបញ្ហាមិនបានបង់ប្រាក់ដើម គ្រឹះស្ថាននឹងទទួលរងការខាតបង់ច្រើន ព្រោះប្រាក់ដើមអតិថិជន មិនបានបង់រំលស់ប្រចាំខែដូចកម្ចីប្រភេទទី១ និង ទី២ ។

#### ១.១.២.៤ ស្ថានភាពទីផ្សារ

ការប្រកួតប្រជែង គឺជាគោលការណ៍គ្រឹះនៅក្នុងរបបទីផ្សារសេរី ក្នុងន័យនេះក្រុមហ៊ុន និងសហគ្រាសទាំងអស់ត្រូវរិះរកវិធីសាស្ត្រយ៉ាងណាអាចគៀងគរអតិថិជនឲ្យបានច្រើន ។ មិនខុសគ្នាទេគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាបានខិតខំពង្រីកទីផ្សាររបស់ខ្លួន តាមរយៈបង្កើតផលិតផលថ្មីៗ ផ្តល់ដែលអត្ថប្រយោជន៍ច្រើនជាងមុន ជូនដល់អតិថិជនបង្កើនគុណភាពនៃផលិតផល និងសេវា ។ ពិសេសជាងនេះទៅទៀត ដើម្បីអាចទាក់ទាញអតិថិជន គ្រឹះស្ថានទាំងនោះបានជ្រើសយកអត្រាការប្រាក់មកធ្វើជាយុទ្ធសាស្ត្រ ។ ជាទូទៅកម្ចីខ្នាតតូច ការប្រាក់ត្រូវបានកំណត់ដោយមិនអាចធ្វើការកែប្រែប្រួល ឬ ចចារបានទេ តែចំពោះកម្ចីខ្នាតធំវិញការប្រាក់អាចធ្វើការចចារ និងកែសម្រួលបាន ។ ការចចារនេះហើយដែលចំណុចមួយយ៉ាងសំខាន់ដែលនាំឲ្យមានការប្រែប្រួលទៅលើការកំណត់ការប្រាក់ ដូច្នេះប្រសិនបើទីផ្សារមានការប្រកួតប្រជែងខ្លាំងការប្រាក់ឥណទានក៏មានការថយចុះតាមនោះផងដែរ ។

## ១.២ ការកំណត់ពិដានអត្រាការប្រាក់

ក្រោយពីមានអនុសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ការកំណត់ពិដានអត្រាការប្រាក់ឥណទាន ត្រូវបានបង្កើតឡើងតាមរយៈប្រកាសរបស់ធនាគារជាតិលេខធ៧-០១៧-១០៩ ប្រ.ក ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៧ ។ ការដាក់ពិដានអត្រាការប្រាក់ឥណទាន គឺជាការដាក់កម្រិតអតិបរមានៃអត្រាការប្រាក់ឥណទាន ដែលគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ អាចកំណត់យកពីអតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថានទាំងនោះ ។[31] កម្រិតអតិបរមានៃអត្រាប្រាក់នោះ គឺ ១៨ (ដប់ប្រាំបី)ភាគរយក្នុងមួយឆ្នាំ ។[32]

នេះជាបរិបទថ្មីមួយ ដែលទាមទារឲ្យគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបត់បែន និង អនុវត្តជាប្រញាប់ក្នុងការកំណត់អត្រាការប្រាក់ឥណទានថ្មី ដែលទើបនឹងដាក់ចុះដោយប្រកាសរបស់ធនាគារជាតិ ។ គ្រឹះស្ថានហិរញ្ញវត្ថុ មានរយៈពេលប្រមាណជាជាងដប់ថ្ងៃប៉ុណ្ណោះ ក្នុងការកែប្រែអត្រាការប្រាក់

[31] សេចក្តីប្រកាសព័តិមានរបស់ធនាគារជាតិនៃកម្ពុជាស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទានចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៧

[32] ប្រការ ៤ នៃប្រកាសស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន ចុះថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៧

ឥណទាន ឲ្យស្របតាមប្រកាសរបស់ធនាគារជាតិ ។ ក្នុងន័យនេះ គ្រឹះស្ថាហិរញ្ញវត្ថុមួយចំនួន បានលើកឡើងពីបញ្ហាប្រឈមរបស់ខ្លួនក្នុងការអនុវត្តពិដានការប្រាក់ថ្មីដែលទើបតែដាក់ឲ្យអនុវត្តនេះ។

### ១.២.១ មូលហេតុនៃការកំណត់ពិដានអត្រាការប្រាក់

ស្របជាមួយបរិបទសកលភាវូបនីយកម្ម រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងរិះរកយុត្តិសាស្ត្រធ្វើយ៉ាងណាជំរុញឲ្យកម្ពុជាដើរទាន់តាមការរីកចម្រើនរបស់ពិភពលោក។ សាក្ខីកម្មដែលបង្ហាញយ៉ាងច្បាស់នោះគឺ យុត្តិសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។ តែយុត្តិសាស្ត្រនេះ ហាក់មានកំណើនយឺត ដោយសារទង្វើរអសកម្ម រួមនឹងបញ្ហាមួយចំនួន ។ ក្នុងនោះបញ្ហាស្នូលមួយដែលនាំឲ្យមាន ការប៉ះពាល់ដល់គោលនយោបាយកាត់បន្ថយភាពក្រីក្រនោះគឺ អត្រាកាប្រាក់ឥណទាន ។ បច្ចុប្បន្នយើងឃើញថា ប្រជាពលរដ្ឋមួយចំនួនបានធ្លាក់ទៅក្នុងស្ថានភាពបំណុលវ័ណ្ឌក ដោយសារតែពួកគាត់ខ្ចីប្រាក់គ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងអត្រាការប្រាក់មួយខ្ពស់ ។ ហេតុផលទាំងនេះហើយ ជាហេតុធ្វើឲ្យប្រជាពលរដ្ឋជាច្រើនបានធ្លាក់ទៅក្នុងភាពក្រីក្រមិនអាចដកខ្លួនបាន ដែលធ្វើឲ្យគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រជួបឧបសគ្គ ។ ដូច្នេះហើយដើម្បី រួមចំណែក ក្នុងការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ និង ការពារប្រជាពលរដ្ឋបញ្ចៀសពីការគិតការប្រាក់ក្នុងអត្រាខ្ពស់ពេកពីសំណាក់គ្រឹះហិរញ្ញវត្ថុ និងជំរុញឲ្យ ការប្រើប្រាស់ឥណទានឲ្យកាន់តែមានប្រសិទ្ធភាព ធនាគារជាតិក៏សម្រេចដាក់ចុះនូវប្រកាស លេខធ៧-០១៧-១០៩ ប្រ.ក ស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាននេះ ដើម្បីកម្រិតអត្រាការប្រាក់ ចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ១.២.២ វិសាលភាពនៃការអនុវត្ត

ប្រកាសស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន មានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើពីសាធារណៈជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ប្រតិបត្តិករឥណទានជនបទ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ។[33]

ការកំណត់អត្រាការប្រាក់ឥណទានមិនឲ្យលើសពី ១៨ ( ដប់ប្រាំបី ) ភាគរយ ក្នុងមួយឆ្នាំនឹងមានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំងឥណទានរៀបចំឡើងវិញ និង មុនហិរញ្ញប្បទាន ដោយមានការចុះហត្ថលេខា និង/ឬ ស្នាមផ្តិតមេដៃ ចាប់ពីថ្ងៃទី០១ ខែមេសា

[33] ប្រការ ៣ នៃប្រកាសស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន

ឆ្នាំ២០១៧តទៅ។[34]មានន័យថា គ្រប់ទម្រង់ទាំងអស់នៃការផ្តល់ឥណទានទាំងថ្មី ទាំងចាស់ ទាំងឥណទានរៀបចំឡើងវិញ ប្រសិនបើកិច្ចសន្យាទាំងនោះមានចុះហត្ថលេខា ឬ/និងផ្តិតមេដៃ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៧តទៅត្រូវអនុវត្តតាមប្រកាសនេះ ពោលគឺត្រូវយកការប្រាក់ពីអតិថិជនរបស់ខ្លួន ក្នុងកម្រិតមមិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ ។ **ឧទាហរណ៍៖** មីង **សំ** បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**ក** ចំនួន១០០០ដុល្លារកាលពីថ្ងៃទី០១ ខែមករា ឆ្នាំ ២០១៧ ក្នុងអត្រាការប្រាក់ ២៤%ក្នុងមួយឆ្នាំ រយៈពេល១២ ខែ ។ បង់បានរយៈពេល ៣ខែ គាត់ក៏មានតម្រូវការបន្ថែម គាត់ក៏ស្នើរទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បី ខ្ចីប្រាក់បន្ថែមចំនួន១០០០ដុល្លារទៀត បន្ថែមលើបំណុលចាស់ ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង មីង**សំ**បានធ្វើកិច្ចសន្យាថ្មីនៅថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៧ ដោយភាគីទាំងពីបានចុះហត្ថលេខា និង ផ្តិតមេដៃក្នុងថ្ងៃតែមួយ ។ ក្នុងករណីនេះ កិច្ចសន្យាដែលបានរៀបចំថ្មីនេះ ត្រូវកំណត់អត្រាការប្រាក់អតិប្បរមាត្រឹម ១៨%ក្នុងមួយឆ្នាំពោលគឺ មិនមែនត្រូវយកតាមអត្រាការប្រាក់ដែលបានកំណត់ក្នុងកិច្ចសន្យាដែលបានធ្វើពីមុននោះទេ ។

### ១.២.៣ ទោសទណ្ឌ

គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិត្រូវអនុវត្តជាកំហិតនូវអត្រាការប្រាក់ឥណទាន ក្នុងកម្រិតមិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ ២០១៧ តទៅ ក្នុងករណីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ទាំងឡាយណាមិនបានអនុវត្តតាមនឹងត្រូវទទួលទណ្ឌកម្មដូចតទៅ ៖

- ការព្រមាន
- ការស្តីបន្ទោស
- ការហាមធ្វើប្រតិបត្តិការមួយចំនួន និងការកំណត់ព្រំដែនដទៃទៀត ក្នុងការធ្វើសកម្មភាព ការព្យួរមុខងារបណ្តោះអាសន្ន ចំពោះអ្នកដឹកនាំម្នាក់ ឬច្រើននាក់ ដោយមានឬដោយគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការឲ្យលាឈប់ពីការងារជាស្វ័យប្រវត្តិ ចំពោះអ្នកដឹកនាំម្នាក់ ឬច្រើននាក់ ដោយមាន ឬគ្មានការតែងតាំងអភិបាលបណ្តោះអាសន្ន
- ការដាក់ឲ្យឋិតនៅក្រោមការគ្រប់គ្រងនៃអភិបាលបណ្តោះអាសន្ន ជាបន្តបន្ទាប់
- ការដកហូតអាជ្ញាប័ណ្ណជាស្ថាពរ និង ការដាក់ឲ្យជម្រះបញ្ជី ។

[34] ប្រការ ៥ នៃប្រកាសស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន

ម៉្យាងទៀត អាជ្ញាធរអាណាព្យាបាលអាចធ្វើការសម្រេច ឬ ដោយជំនួស ឬ ដោយបន្ថែមលើទណ្ឌកម្មទាំងនេះ នូវការពិន័យជាប្រាក់យ៉ាងច្រើនបំផុតត្រឹមស្មើរនឹងដើមទុនអប្បរមាដែលតម្រូវឲ្យគ្រឹះស្ថាននោះអនុវត្ត ។[35]

### ១.២.៤ គតិយុត្តិភាពនៃការអនុវត្ត

ធនាគារជាតិនៃកម្ពុជា អនុវត្តមុខងារជាអាជ្ញាធរត្រួតពិនិត្យរបស់ខ្លួនជាប្រចាំដើម្បីធានាដល់ការអនុវត្តរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុប្រកបដោយតម្លាភាព សុវត្ថិភាព និង ភាពរឹងមាំក៏ដូចជាពង្រឹងជំនឿទុកចិត្ត របស់សាធារណជនមកលើប្រពន្ធគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និង ធានាបានថា គ្រប់បទដ្ឋានគតិយុត្តិដែលមានជាធរមានត្រូវបានអនុវត្តត្រឹមត្រូវ ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជា ធ្វើការត្រួតពិនិត្យតាមរយៈវិធីសាស្ត្រនៃការត្រួតពិនិត្យ លើការអនុវត្តតាមច្បាប់ និង បទប្បញ្ញត្តិ និង ការត្រួតពិនិត្យផ្អែកលើហានិភ័យ ។ ការត្រួតពិនិត្យ ត្រូវបានអនុវត្តទាំងលើការត្រួតពិនិត្យលើឯកសារ និង ការត្រួតពិនិត្យដល់ទីកន្លែង តាមរយៈនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា ។

#### ១.២.៤.១ នីតិកម្ម

នាយកដ្ឋាននីតិកម្ម ជានាយកដ្ឋានមួយដែលឋិតនៅក្រោមការគ្រប់គ្រងនៃអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា ដែលមានមុខងារ ភារកិច្ចចម្បងក្នុងការរៀបចំពិនិត្យឡើងវិញនូវច្បាប់ និង បទប្បញ្ញត្តិ អនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សិក្សា ពិគ្រោះ និង ផ្តល់យោបល់លើឯកសារច្បាប់ និង បទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ លើសពីនេះ នាយកដ្ឋាននីតិកម្ម ក៏មានមុខងារ-ភារកិច្ច ពិគ្រោះ និង ផ្តល់យោបល់ពីនីតិវិធីដោះស្រាយតាមរយៈតុលាការមធ្យោបាយផ្សេងៗទៀត ដែលទាក់ទងទៅនឹងបញ្ហាគតិយុត្តិនិងវិវាទរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធផ្សេងៗ ព្រមទាំង តាមដានរាល់ការអនុវត្តច្បាប់ និង បទញ្ញត្តិទាំងឡាយ ដែលបានប្រកាសឲ្យអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុពិសេសបញ្ញត្តិទាំងឡាយដែលទាក់ទងទៅនឹងការកំណត់អត្រាការប្រាក់ ។

#### ១.២.៤.២ ត្រួតពិនិត្យដល់ទីកន្លែង

ជាទូទៅការត្រួតពិនិត្យដល់ទីកន្លែង ត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានប្រចាំឆ្នាំ និង តាមការចាំបាច់ ដែលអាចជា ការត្រួតពិនិត្យពេញលេញ និង តាមមុខសញ្ញា ។

[35] មាត្រា ៥២នៃច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ

នាយកដ្ឋានត្រួតពិនិត្យដល់ទីកន្លែង ជានាយកដ្ឋានមួយរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលមានតួនាទីសំខាន់ក្នុងការការពារ និង ពង្រឹងប្រព័ន្ធធនាគារនៅកម្ពុជា តាមរយៈ៖

- បង្កើតយុទ្ធសាស្ត្រ និងអនុវត្តផែនការត្រួតពិនិត្យដល់ទីកន្លែងដោយផ្អែកលើហានិភ័យ ទំហំ និង ភាពស្មុគស្មាញនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
  ចេញរបាយការណ៍ត្រួតពិនិត្យដល់ទីកន្លែង អនុវត្តវិធានការណ៍កែតម្រូវ តាមដានការអនុវត្ត អនុសាសន៍ត្រួតពិនិត្យដល់ទីកន្លែងនិងព្យាករណ៍ហានិភ័យ
- សហប្រតិបត្តិការជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នាយកដ្ឋានផ្សេងៗ និងអាជ្ញាធរត្រួតពិនិត្យទាំងក្នុងនិងក្រៅប្រទេស
- ធានាដល់ការអនុវត្តតាមច្បាប់ និង បទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា រួមទាំងបញ្ញត្តិទាក់ទងទៅនឹងអត្រាការប្រាក់ផងដែរ ។

### ១.២.៤.៣ ត្រួតពិនិត្យឯកសារ

ការត្រួតពិនិត្យលើឯកសារ ត្រូវបានធ្វើឡើងជាអចិន្ត្រៃយ៍ ចំពោះគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុដោយអនុលោមតាមច្បាប់ និង បទបញ្ញត្តិ តាមរយៈការតាមដាន ពិនិត្យ និង វិភាគលើព័ត៌មាននិងរបាយការណ៍ ប្រចាំការ និងតាមការចាំបាច់ ។ ទន្ទឹមនឹងនេះ មន្ត្រីធនាគារជាតិនៃកម្ពុជាក៏ជួបប្រជុំជាមួយគណៈគ្រប់គ្រង និង/ឬ បុគ្គលិក របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងគោលបំណងសិក្សាស្វែងយល់ពីអាជីវកម្ម និង ទស្សនៈវិស័យអាជីវកម្មរបស់គ្រឹះស្ថាននីមួយៗទៅតាមការចាំបាច់។

នាយកដ្ឋានត្រួតពិនិត្យលើឯកសារ ជានាយកដ្ឋានមួយស្ថិតក្រោមការ អគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលមានតួនាទី ត្រួតពិនិត្យ តាមដាន និង វិភាគជាប្រចាំលើប្រតិបត្តិការ និង របាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ពិសេសរបាយការណ៍ក្នុងការកំណត់អត្រាការប្រាក់ ដើម្បីធានាដល់ការអនុឡោមតាមច្បាប់ និង បទប្បញ្ញត្តិទាំងឡាយ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា និង ធានាដល់ការអនុវត្តរបស់គ្រឹះស្ថានប្រកបដោយសុវត្ថិភាព និង ភាពរឹងមាំ ។ ក្រៅពីនេះតួនាទីទាំងអស់នេះ នាយកដ្ឋានត្រួតពិនិត្យលើឯកសារ មានមុខងារសំខាន់ផ្សេងទៀត គឺធ្វើការសិក្សា និង ឆ្លើយតបទៅនឹងរាល់សំណើរសុំនានារបស់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។

### ១.២.៥ ផលវិបាកនៃការដាក់ពិដានអត្រាការប្រាក់ឥណទាន

ត្រង់ចំណុចនេះ យើងឃើញថាក្រោយពីមានការចេញនូវប្រកាសរបស់ធនាគារជាតិ ស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទាន មានបញ្ហាចម្រូងចម្រាស់គ្នាណាស់ចំពោះ ផលវិជ្ជមាន និង ផលអវិជ្ជមានក្នុងអនុវត្តប្រកាសនេះ ។

#### ១.២.៥.១ គុណសម្បត្តិ

ជាការពិត ការដាក់ពិដានការប្រាក់វាមិនមែនជារឿងថ្មីនោះទេ ដោយសារតែក្នុងពេលគន្លងមកយើងឃើញមានប្រទេសចំនួនជាង៦០ ក្នុងចំណោមប្រទេសជាសមាជិកនៃធនាគារពិភពលោក សរុបចំនួន ១៥២ប្រទេស ក៏មានការដាក់ពិដានអត្រាការប្រាក់ឥណទាននេះដែរ ដោយសារតែតាមទ្រឹស្តី ការដាក់ពិដានអត្រាការប្រាក់មានសារៈប្រយោជន៍ខ្លាំងណាស់ ។[36] សារៈប្រយោជន៍ទាំងនោះរួមមាន៖

- **ការការពារអតិថិជនពីការគិតការប្រាក់ខ្ពស់ហួសហេតុពេក:** ជាការពិតប្រសិនបើមិនមានការកំណត់ពិដានអត្រាការប្រាក់ឥណទាននោះទេ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងនោះអាចធ្វើការកំណត់អត្រាការប្រាក់បានស្រេចតែទំនើងចិត្ត ដែលជាហេតុធ្វើឲ្យអតិថិជន ពិសេសប្រជាពលរដ្ឋក្រីក្រដែលមិនមានការយល់ដឹង ទូលំទូលាយពាក់ព័ន្ធនឹងរឿងការប្រាក់ក្លាយជាជនរងគ្រោះ ដោយសារតែការប្រាក់ខ្ពស់ ។
- **បង្កើនលទ្ធភាពទទួលបានឥណទាន:** ជាមួយគ្នានឹងការថយចុះនូវការប្រាក់អតិថិជន អាចមានភាពធូរស្រាល ចំពោះបន្ទុករបស់ខ្លួនក្នុងការបង់ប្រាក់ទៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដូចនេះគាត់អាចខ្ចីប្រាក់បន្ថែមដើម្បីយកទៅបំពេញតម្រូវការតាមលទ្ធភាពរបស់ខ្លួន ។
- **ការផ្តល់កម្ចីកាន់តែមានភាពងាយស្រួល:** ជាការពិតណាស់ អត្រាប្រាក់ទាបវានឹងអាចបង្កភាពងាយស្រួលក្នុងការទទួលបានឥណទាន អាចទទួលបានឥណទានកាន់តែមានទំហំធំជាងមុន ។
- **កាត់បន្ថយភាពក្រីក្រ:** ជាការពិតណាស់ នៅពេលអត្រាការប្រាកស្ថិតក្នុងទំហំមួយសមរម្យប្រជាពលរដ្ឋគាត់អាចកាត់បន្ថយការបង់ការប្រាក់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហើយពិសេសគាត់អាចខ្ចីប្រាក់បន្ថែម ដើម្បីយកមកពង្រីកអាជីវកម្មរបស់គាត់ទៅតាមលទ្ធភាពដែលជំរុញឲ្យជីវភាពរបស់ពួកគាត់កាន់តែមានភាពប្រសើរឡើងមួយកម្រិតថែមទៀត ។

[36] ការផ្សាយរបស់វិទ្យុVOA នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៧ ( រាយការណ៍ដោយកញ្ញា ខាន់ សុគុំមនោ )

### ១.២.៥.២ គុណវិបត្តិ

ទន្ទឹមនឹងគុណសម្បត្តិដែលទទួលបានពីការដាក់ពិដានអត្រាការប្រាក់ វាក៏មានផលអវិជ្ជមានមួយចំនួនផងដែរ ។ ផលអវិជ្ជមានទាំងនោះរួមមាន ៖

- **រារាំងដល់លទ្ធភាពទទួលបានឥណទាននៅទីជនបទ និង តំបន់ងាយរងគ្រោះ:** នៅពេលដែលមានការកំណត់ពិដានអត្រាការប្រាក់ឥណទាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ច្បាស់ជាមានការកាត់បន្ថយការផ្តល់កម្ចីខ្នាតតូច ឬឈប់ផ្តល់តែម្តង ដោយហេតុតែកម្ចីទំហំតូច ចំណាយប្រតិបត្តិការខ្ពស់ អត្រាការប្រាក់ក៏ទាប ហើយប្រឈមទៅនឹងហានិភ័យខ្លាំងថែមទៀត ។ ក្នុងន័យនេះ អតិថិជនកម្ចីខ្នាតតូចភាគច្រើន ជាប្រជាពលរដ្ឋក្រីក្រដែលត្រូវការទុនយកទៅពង្រីកមុខរបរ ធ្វើកសិកម្មជាដើម ពួកគាត់នឹងបាត់បង់ឱកាសដើម្បីស្តារជីវភាពរបស់ខ្លួន ដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឈប់ផ្តល់កម្ចីខ្នាតតូច ងាកទៅរកការផ្តល់កម្ចីខ្នាតធំដែលអតិថជន គោលដៅគឺជាអ្នកមាន ។
- **ការកើនឡើងនូវការខ្ចីប្រាក់ដោយខុសច្បាប់:** ជាមួយគ្នានឹងការបាត់បង់ឱកាសក្នុងទទួលបានឥណទានខ្នាតតូចពីគ្រឹះស្ថានមីក្រហិរញ្ញវត្ថុ ប្រជាពលរដ្ឋនឹងងាកទៅរកការខ្ចីប្រាក់ពីអ្នកចងការឯកជន ឬការចងការប្រាក់ខុសច្បាប់ ដោយសារតែការចងការប្រាក់ទាំងនោះវាមានភាពងាយស្រួល មិនត្រូវការឯកសារស្មុគស្មាញ឴ ឆាប់រហ័ស និង ផ្តល់ជូនកម្ចីគ្រប់ទំហំទោះពួកគាត់ដឹងយ៉ាងច្បាស់ថា មានអត្រាការប្រាក់ខ្ពស់ក៏ដោយ ។
- **បង្កើនថ្លៃចំណាយលើប្រតិបត្តិការ:** ជាទូទៅនៅតាមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានការគិតកម្រៃប្រតិបត្តិការចំពោះអតិថិជនដែលបានខ្ចីប្រាក់ពីគ្រឹះស្ថានរបស់ខ្លួនដូច្នេះ ប្រសិនបើការប្រាក់មានការថយចុះខ្លាំងគ្រឹះស្ថានទាំងនោះនឹងតម្លើងថ្លៃកម្រៃប្រតិបត្តិការរបស់ខ្លួន ឬ បង្កើតការចំណាយផ្សេងទៀត ដែលពីមុនមិនមាន បន្ថែមលើតម្លៃប្រតិបត្តិការ ដែលមានស្រាប់ដើម្បីធ្វើយ៉ាងណាអាចឲ្យផលចំណេញ និង ថ្លៃចំណាយផ្សេងៗមានសមាមាត្រគ្នា ។
- **រំខានដល់ការច្នៃប្រឌិតផលិតផលហិរញ្ញវត្ថុ:** ជាការពិតក្នុងបរិបទទីផ្សារសេរី ការប្រកួតប្រជែង គឺជាចំណុចមួយដែលមិនអាចខ្វះបាននោះទេ មានន័យថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនីមួយៗត្រូវរិះរកមធ្យោបាយ ធ្វើយ៉ាងឲ្យផលិតផលហិរញ្ញវត្ថុរបស់ខ្លួនកាន់តែងាយស្រួល មានច្រើនជម្រើស និងផ្តល់ផលចំណេញសម្រាប់អតិថិជន ។ តែក្នុងពេលនេះការច្នៃប្រឌិតផលិតផលហិរញ្ញវត្ថុអាចធ្វើឡើងក្រោមរូបភាពផ្សេងៗជាអាទិ៍ដូចជា ការកែច្នៃដើម្បីការពារ

ហានិភ័យ បន្ថយការចំណាយរបស់គ្រឹះស្ថាន បន្ថែមការចំណាយផ្សេងៗសម្រាប់អតិថិជន ជាដើម ។

– **បង្កើនការចំណាយដល់អ្នកខ្ចីប្រាក់ចំពោះថ្លៃចំណាយ ដែលមិនពាក់ព័ន្ធនឹងការប្រាក់:** ក្នុងកាលៈទេសៈបែបនេះគ្រឹះស្ថានហិរញ្ញវត្ថុនីមួយៗ ត្រូវរិះរកគ្រប់មធ្យោបាយធ្វើយ៉ាងណាអាចឲ្យខ្លួនមានប្រតិបត្តិការ និង រក្សាបាននូវតុល្យភាពរវាងការចំណាយ និង ប្រាក់ចំណូល ។ បើដូច្នោះ ដំណោះស្រាយមួយដែលមានប្រសិទ្ធិភាពគឺ បង្កើតឡើងនូវការចំណាយផ្សេងៗរបស់អតិថិជន ដែលមិនពាក់ព័ន្ធនឹងការប្រាក់ ។ ការចំណាយទាំងនោះមានដូចជា កម្រៃប្រតិបត្តិការប្រចាំខែ ឬក៏កាតម្រូវឲ្យអតិថិជនដាក់តម្កល់ប្រាក់របស់ខ្លួនក្នុគណនេយ្យសន្សំ ( សន្សំជាប់កម្ចី ) ។

ម្យ៉ាងវិញទៀត ការដាក់ពិដានអត្រាការប្រាក់ក៏មានផលប៉ះពាល់ដល់ការវិនិយោគនៅកម្ពុជាផងដែរ ជាពិសេសគឺវិនិយោគិនបរទេស ដែលបានមកវិនិយោគ ឬត្រៀមបម្រុងមកវិនិយោគនៅកម្ពុជា ព្រោះការដាក់ពិដានអត្រាការប្រាក់ហាក់ដូចជាមានភាពប្រញាប់ប្រញាល ដោយគ្មានការព្រួយបារម្ភពីអ្នកវិនិយោគិន ។ យ៉ាងណាមិញ ការដាក់ពិដានអត្រាប្រាក់នេះនឹងធ្វើឲ្យមានការប៉ះពាល់ដល់រចនាសម្ព័ន្ធ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជាផងដែរ ។

## ១.៣ ការគណនាការប្រាក់ឥណទាន

បច្ចុប្បន្នធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានបានចុះបញ្ជី និង បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និង សមាគមចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់ លើឥណទានរបស់ខ្លួនដោយអនុឡោមតាមប្រកាសលេខ ធ៧-០១-១១៥ ប្រ.ក ស្តីពីការគណនាការប្រាក់ចំពោះឥណទាន មីក្រូហិរញ្ញវត្ថុ ។

យោងតាមប្រកាសនេះ ការគណនាការប្រាក់ចំពោះឥណទាន ដែលបានផ្តល់ដោយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយបាន ន័យថាការប្រាក់លើឥណទានសម្រាប់រយៈពេលមួយជាកំណត់ ( សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ ។[37]

[37] ប្រការ ២នៃប្រកាសស្តីពី ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

គ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅពេលបង្កើតកិច្ចសន្យាខ្ចីប្រាក់រវាងគ្រឹះស្ថាន និងអតិថិជន ត្រូវផ្តល់ជូនដល់អតិថិជនរបស់ខ្លួននូវតារាងនៃការបង់សងរំលោះឥណទាន ហើយក្នុងតារាងបង់ប្រាក់នេះទៀតសោត ត្រូវបង្ហាញអត្រាការប្រាក់ប្រចាំខែ រួមទាំងកម្រៃផ្សេងៗដែលគ្រឹះស្ថានបានទទួលពីអតិថិជន ។

ការគណនាអត្រាការប្រាក់ជាទូទៅ ត្រូវគណនាដោយយកចំនួនប្រាក់ដើម ឬវត្ថុដើមដែលជំពាក់ជាក់ស្តែង ទៅគុណជាមួយនឹងអត្រាការប្រាក់ដែលភាគីបានព្រមព្រៀងគ្នា ឬ តាមការកំណត់របស់ច្បាប់ ។ គួររំលឹកផងដែរថា អត្រាការប្រាក់ជាទូទៅច្រើនគិតអត្រាក្នុងមួយខែ ព្រោះជាធម្មតាគូភាគី តែងកំណត់ការសងក្នុងមួយខែម្តងពោលគឺ កូនបំណុលត្រូវបង់សងទៅម្ចាស់បំណុលវិញជារៀងរាល់ខែ ប៉ុន្តែតាមច្បាប់វិញអត្រាការប្រាក់ត្រូវគិតជាឆ្នាំកូនបំណុលត្រូវបង់ការប្រាក់មួយឆ្នាំម្តង ។

**រូបមន្តគណនាអត្រាការប្រាក់:** ( ករណីបង់ការប្រាក់ប្រចាំខែ )

$$I = P \times R \times t / 30$$

**I**: ជាការប្រាក់ដែលត្រូវទទួល ឬការប្រាក់ដែលអតិថិជនត្រូវសង

**P**: ជាចំនួនប្រាក់ដើមដែលជំពាក់ជាក់ស្តែង

**R**: ជាអត្រាការប្រាក់ប្រចាំខែ

**t**: ចំនួនថ្ងៃដែលបានជំពាក់

**ឧទាហរណ៍៖** លោក **ក** បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ខ** នូវចំនួនទឹកប្រាក់ ១០០០ ដុល្លារ ក្នុងអត្រាការប្រាក់១.៥%ក្នុង១ខែនៃប្រាក់ដើម រយៈពេល២៤ខែ។ ក្នុងកិច្ចសន្យាបានបញ្ជាក់ថា លោក **ក** ត្រូវបង់ប្រាក់ដើមនឹងការប្រាក់ជារាល់ខែ។

តាមករណីខាងលើ ការប្រាក់ដែលលោក **ក** ត្រូវបង់ទៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងខែទី១គឺ៖

តាមរូបមន្ត: I = P x R x t /30

P = ១០០០

R = ១.៥%

t = ៣០

⇨ ការប្រាក់ដែលត្រូវបង់ខែទី១= ១០០០ x១.៥% x៣០/៣០=១៥$

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

អ្វីដែលយើងទទួលបានពីស្នាដៃសារណានេះ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្តល់ជាចំណេះដឹងជុំវិញបញ្ហាការប្រាក់ និង ជាចលករជំរុញឲ្យសង្គមកាន់តែមានរីកចម្រើនថែមមួយកម្រិតទៀត ។ ស្នាដៃនេះ បានឆ្លុះបញ្ចាំងពីតថភាពពិត ដែលកំពុងតែកើតមាននៅក្នុងសង្គមនាពេលបច្ចុប្បន្ន ក្នុងវិស័យឥណទាន ។ ស្របជាមួយគ្នានេះផងដែរ យើងសង្កេតឃើញថាការចងការប្រាក់នៅកម្ពុជា សព្វថ្ងៃនេះមានច្រើនសណ្ឋាន និងឋិតក្រោមការគ្រប់គ្រងរបស់បទដ្ឋានគតិយុត្តិផ្សេងៗ ។ ក្នុងន័យនេះ អត្រាការប្រាក់ត្រូវបានកំណត់ដោយច្បាប់ពីរផ្សេងគ្នា មួយជាអត្រាការប្រាក់ ដែលកំណត់ដោយក្រមរដ្ឋប្បវេណី ដែលអនុវត្តសម្រាប់ការចង់ការប្រាក់ឯកជនទូទៅ និង មួយទៀតជាអត្រាការប្រាក់ដែលកំណត់ ដោយធនាគារជាតិអនុវត្តសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ។ ត្រង់នេះហើយដែលមហាជនមួយចំនួន បានលើកឡើងថា មិនសមណា បើកឱកាសឲ្យធនាគារជាតិ ធ្វើការកំណត់ការប្រាក់ដោយឡែក ដូច្នេះនោះទេ គួរណាតែទុកឲ្យក្រមរដ្ឋប្បវេណីកំណត់វិញ ទើបមានភាពប្រសើរជាង ។ ប៉ុន្តែប្រសិនបើ យើងសិក្សាឲ្យបានស៊ីជម្រៅទៅយើងឃើញថា ក្រមរដ្ឋប្បវេណី ជាបញ្ញត្តិរួមនៃនីតិឯកជន ដូច្នេះហើយប្រសិនជាមានច្បាប់ពិសេសណាមួយកំណត់ និង គ្រប់គ្រងទៅលើសកម្មភាពអ្វីមួយនោះ ក្រមរដ្ឋប្បវេណីមិនមានអានុភាពទៅអនុវត្តលើសកម្មភាពទាំងនោះនោះទេពោលគឺបញ្ញត្តិពិសេសទាំងនោះមានសុពលភាពអនុវត្ត ។

ស្របជាមួយនឹងបរិបទសាកលភាវូបនីយកម្ម យើងសង្កេតឃើញថារាជរដ្ឋាភិបាលកម្ពុជាបានខិតខំ ធ្វើយ៉ាងណាឲ្យវិស័យចងការប្រាក់នៅកម្ពុជាមានការរីកចម្រើន តាមរយៈការបញ្ចុះអត្រាការប្រាក់ និង ពង្រឹងការយល់ដឹងដល់ប្រជាពលរដ្ឋដោយជំរុញ សំដៅធ្វើយ៉ាងឲ្យប្រជាពលរដ្ឋប្រើប្រាស់ សេវាកម្មឥណទានប្រកបដោយប្រសិទ្ធិភាព ។ ជាក់ស្តែង ថ្មីៗនេះប្រមុខរាជរដ្ឋាភិបាលបានចេញអនុសាសន៍ឲ្យធនាគារជាតិ កំណត់អត្រាការប្រាក់ត្រឹម១៨% ក្នុង១ឆ្នាំ ហើយគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុទាំងអស់ ដែលឋិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិក៏បានអនុវត្តអត្រាការប្រាក់នេះ ចាប់តាំងពី ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៧ តមក ។ ក្នុងន័យនេះ ប្រជាពលរដ្ឋទូទៅបានសាទរនឹងសមិទ្ធផលថ្មីនេះព្រោះអាចពួកអាចកាត់បន្ថយចំណាយការបង់ប្រាក់ទៅធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

ទន្ទឹមនឹងផ្លែផ្កាជាវិជ្ជមានជាច្រើនដូចបានរៀបរាប់ខាងលើ យើងក៏បានសង្កេតឃើញមានភាពអសកម្មមួយចំនួនផងដែរ ។ ក្រោយពីមានការប្រកាសអំពីពិដានអត្រាការប្រាក់ គ្រឹះស្ថាន

ធនាគារ និង ហិរញ្ញវត្ថុ មួយចំនួនបានត្អូញត្អែរពីបញ្ហាប្រឈមរបស់ខ្លួន ។ គ្រឹះស្ថានទាំងនោះត្រូវប្រឈមនឹងការទម្លាក់អត្រាការប្រាក់ចុះយ៉ាងគំហុគ ដែលស្របនឹងការចំណាយរបស់ខ្លួនបានបន្តកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ ពិសេសជាងនេះទៀតការផ្លាស់ប្តូរការប្រាក់នេះ វាហាក់ដូចជាមានភាពតក់ក្រហល់ខ្លាំងណាស់ ព្រោះពួកគេមានរយៈពេលប្រមាណជាពីរសប្តាហ៍ តែប៉ុណ្ណោះក្នុងការ កែប្រែលអត្រាការប្រាក់ដែលមានស្រាប់ ។ ទាំងនេះហើយ ជាហេតុធ្វើឲ្យមានការប៉ះពាល់យ៉ាងខ្លាំងដល់រចនាសម្ព័ន្ធគ្រឹះស្ថានទាំងនោះយ៉ាងខ្លាំង ។ ក្នុងន័យនេះ យើងអាចស្រមើលស្រមៃបន្តិចថា ប្រសិនបើ គ្រឹស្ថានទាំងនោះមួយចំនួនបានក្ស័យធនតើបញ្ហាអ្វីអាចនឹងកើតឡើង ? ជាការពិតណាស់ នៅពេល ដែលមានការដាក់ពិដានអត្រាការប្រាក់ គ្រឹះស្ថានដែលមានផលប៉ះពាល់ខ្លាំងជាងគេ គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករតូចៗ ដែលកំពុងប្រតិបត្តិការផ្តល់កម្ចីខ្នាតតូចជូនដល់ ប្រជាពលរដ្ឋក្រីក្រ ភាគច្រើននៅតាមតំបន់ជនបទ ស្រុកស្រែ ចំការតំបន់ដាច់ស្រយាល ។ ហេតុដូច្នេះហើយ ប្រសិនបើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ប្រតិបត្តិករទាំងនេះក្ស័យធន អ្នកដែលរងគ្រោះគឺប្រជាពលរដ្ឋក្រីក្រ ដោយសារតែនៅពេលគ្រឹស្ថានទាំងនោះក្ស័យធន ពួកគាត់នឹងងាកទៅរកការចងការប្រាក់ឯកជន ដែលមានអត្រាការប្រាក់ថ្លៃ ។ ជាមួយគ្នានេះគ្រឹស្ថានហិរញ្ញវត្ថុដែលបន្តប្រតិបត្តិការរបស់ខ្លួន នឹងទៅរកកម្ចីខ្នាតធំ ដោយផ្តល់កម្ចីដល់ជនដែលមានចំនូលខ្ពស់ ។

ម្យ៉ាងវិញទៀត សម្រាប់ការអនុវត្តក្នុងពេលបច្ចុប្បន្នយើងសង្កេតឃើញថា មិនមានយន្តការណាមួយក្នុងការតាមដានចំពោះការចង់ការប្រាក់ឯកជននោះទេ ។ យ៉ាងណាមិញសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ ដែលឋិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិកន្លងមកបានអនុវត្តយ៉ាងល្អប្រសើរក្នុងការកំណត់អត្រាការប្រាក់ និង ធ្វើយ៉ាងណាបញ្ចៀសបំណុលវ័ណ្ឌករបស់អតិថិជន ព្រោះតែធនាគារជាតិមានយន្តការក្នុងការតាមដានចំពោះដំណើរការ និងការប្រព្រឹត្តទៅនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពិសេសបញ្ហាអត្រាការប្រាក់ ដោយឡែកចំពោះការចង់ការប្រាក់ឯកជនវិញ មិនមានយន្តការដើម្បីតាមដាននោះទេ ។ យើងឃើញនៅក្នុងប្រកាស ដែលចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានកំណត់អត្រាការប្រាក់ដែលអនុវត្តតាមកិច្ចសន្យា ត្រឹមកម្រិត ១៨% ក្នុង១ឆ្នាំពិតមែន តែជាក់ស្តែងអត្រាការប្រាក់ ដែលអនុវត្តសម្រាប់ការចងការប្រាក់ឯកជន នាពេលបច្ចុប្បន្នគឺ អាចដល់២៤០%ក្នុងមួយឆ្នាំក៏មាន ។ ក្នុងន័យនេះ ប្រជាពលរដ្ឋមួយចំនួនបានធ្លាក់ទៅក្នុង ស្ថានភាពបំណុលវ័ណ្ឌក ដោយសារតែការចងការប្រាក់ឯកជន និង ការចងការប្រាក់ផ្សេងទៀតបង្កើតឡើងខុសច្បាប់ ។

ជាមួយគ្នានឹងបញ្ហាដែលបានលើកឡើងខាងលើយើងឃើញថា ប្រជាពលរដ្ឋមួយចំនួនទទួលបានព័ត៌ឥណទានហាក់នៅមានកម្រិត និង មិនមានចំនេះដឹងគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ឥណទានប្រកបដោយប្រសិទ្ធិភាព ពួកគាត់មួយចំនួនបានប្រើប្រាស់ឥណទានដែលទទួលបាន ទៅទិញសម្ភារៈលម្អរកាយផ្សេងៗ ដោយមិនគិតយកប្រាក់ដែលបានខ្ចីទៅពង្រីករបរ ឬបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារនោះទេ ។ នេះឆ្លុះបញ្ចាំងឲ្យយើងឃើញយ៉ាងច្បាស់ថាប្រជាពលរដ្ឋនៅមានចំនេះដឹងតិចតួចនៅឡើយចំពោះការប្រើប្រាស់ឥណទាន ដែលទាមទារឲ្យមានដំណោះមួយសមរម្យ ។

ជារួមយើងអាចនិយាយបានថា ប្រតិបត្តិការឥណទាននៅកម្ពុជានឹងអាចមានភាពរីកចម្រើនប្រជាពលរដ្ឋ អាចទទួលយកនូវសេវាឥណទានប្រកបដោយប្រសិទ្ធិ និង កាត់បន្ថយភាពក្រីក្រ គឺទាមទារឲ្យមានការបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធភាព លុបបំបាត់ឲ្យអស់រាល់គ្រប់ទម្រង់នៃការចងការប្រាក់ដែលខុសច្បាប់ និង បង្កើតនូវ យន្តការមួយក្នុងការតាមដាន នូវរាល់ប្រតិបត្តិការឥណទានគ្រប់ទម្រង់ ធ្វើយ៉ាងណាធានាឲ្យបានថារាល់ច្បាប់ និង បទដ្ឋានគតិយុត្តិទាំងអស់ ដែលមានជាធរមានត្រូវបានអនុវត្តត្រឹមត្រូវពីសំណាក់បុគ្គល និង ស្ថាប័នដែលពាក់ព័ន្ធ ។

# ឯកសារយោង

# ឯកសារយោង

## ១. ឯកសាច្បាប់


- ក្រមរដ្ឋប្បវេណី លេខនស/រកម/១២០៧/០៣០ ឆ្នាំ២០០៧
- ច្បាប់ស្តីពី គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ លេខនស/រកម/១១៩៩/១៣ ឆ្នាំ ១៩៩៩
- ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាលេខនស/រកម/០១៩៦/២៧ ឆ្នាំ១៩៩៦
- ប្រកាសស្តីពី ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ លេខ ធ៧-០៩-២១៣ ប្រ.ក ឆ្នាំ២០០៩
- ប្រកាសស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទានលេខធ៧-០១៧-១០៩ប្រ.កឆ្នាំ២០១៧
- ប្រកាសស្តីពី ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុលេខធ៧-០១-១១៥ប្រ.ក ឆ្នាំ២០០១
- ប្រកាសស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ១២៨ កយ.ប្រក/១១ ឆ្នាំ ២០១១
- សេចក្តីប្រកាសព័ត៌មានស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន ( គ្មានលេខ ) ឆ្នាំ ២០១៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ដែលរៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពី ការអនុវត្តក្រមរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការទទួលបន្ទុកកិច្ចការផ្នែកច្បាប់រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនដែលទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០១១


## ២. សៀវភៅ


- សៀវភៅសិក្សាស្តីពី « *កិច្ចសន្យាពិសេស* » របស់លោក ស សូវាទ បោះពុម្ពឆ្នាំ២០១៣
- សៀវភៅសិក្សាស្តីពី « *កិច្ចសន្យាពិសេស* » របស់លោក អៀង សំណាង បោះពុម្ពឆ្នាំ២០១៤


## ៣. គេហទំព័រ


- https://www.nbc.org.kh/supervision/licensing_department.php
- http://khmer.voanews.com/a/possibility-of-interest-rate-cap-in-cambodia-is-too-early-to-expect-say-an-observer/3261598.html

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ឯកសារច្បាប់

## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ: ១២៨ យ.ក/ប្រក/១១

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ ៨ ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## អត្រាការប្រាក់ដែលត្រូវបានកម្រិត

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី

### សម្រេច

ប្រការ ១.-

អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិត ជាអាទិ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង ១ (មួយ) ឆ្នាំ។

ប្រការ ២.-

អត្រាការប្រាក់ ដែលព្រមព្រៀងជាមុនក្នុងការសងសំណងក្នុងកិច្ចសន្យាខ្ចីបរិភោគដែលមានកម្មវត្ថុជាប្រាក់ ដែលបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវ

បានកម្រិត ជាអាទ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឲ្យលើសពីចំនួន ១,៥ (មួយក្បៀសប្រាំ) ដង នៃអត្រាការប្រាក់ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ។

**ប្រការ ៣.-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

អង្គ វង្សវឌ្ឍានៈ

ចម្លងជូន៖

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការ -អយ្យការអមតុលាការគ្រប់ជាន់ថ្នាក់

-ឯកសារ-កាលប្បវត្តិ។

ធ៧-០៩-២១៣ ប្រ.ក

# ប្រកាស
# ស្តីពី
# ការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់

**ប្រការ ១** .-

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានសិទ្ធិក្នុងការកំណត់នូវអត្រាការប្រាក់លើប្រាក់បញ្ញើ និងការផ្តល់ឥណទានជាប្រាក់រៀលនិងជារូបិយប័ណ្ណ យោងតាមលទ្ធភាព និងគោលនយោបាយអត្រាការប្រាក់របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នីមួយៗ។

**ប្រការ ២** .-

រាល់ដំណាច់ខែនីមួយៗ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីអត្រាការប្រាក់ជាមធ្យមដែលបានអនុវត្តលើប្រាក់បញ្ញើ និងការផ្តល់ឥណទានមកធនាគារជាតិនៃកម្ពុជា។

**ប្រការ ៣** .-

ប្រកាសលេខ ធ៥-៩៥-៤៧ ប្រ.ក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបើកទូលាយក្នុងការកំណត់អត្រាការប្រាក់ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤** .-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាពគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៥** .-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-១០៩ ប្រ.ក

# ប្រកាស
## ស្តីពី
## ការកំណត់ពិដានអត្រាការប្រាក់ឥណទាន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- យោងប្រកាសលេខ ធ៨-៩៨-៣៨៥ ប្រ.ក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជានិងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងប្រកាសលេខ ធ១-០១០-១៩៤ ប្រ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការកែសម្រួល ប្រការ ៣ ប្រការ ៤ ប្រការ ៥ ប្រការ ១២ និងប្រការ ១៣ នៃប្រកាសស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់ពិដានអត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ហើយធ្វើប្រតិបត្តិការឥណទានជនបទ តទៅនេះហៅថា "គ្រឹះស្ថាន"។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅការពារអតិថិជនពីការគិតអត្រាការប្រាក់ខ្ពស់ពេកពីគ្រឹះស្ថាន និងជំរុញការប្រើប្រាស់ឥណទានឲ្យមានប្រសិទ្ធភាព។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា។

**ប្រការ ៤.-**

គ្រឹះស្ថានត្រូវកំណត់អត្រាការប្រាក់ឥណទាន មិនឲ្យលើសពី ១៨% ( ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំសម្រាប់គ្រប់ឥណប្រតិទាននៃឥណទាន។

**ប្រការ ៥.-**

ការកំណត់អត្រាការប្រាក់ឥណទានដូចមានចែងក្នុងប្រការ ៤ ខាងលើនេះ មានប្រសិទ្ធភាពអនុវត្តចំពោះកិច្ចសន្យាឥណទានថ្មី រួមទាំង ឥណទានរៀបចំឡើងវិញ (Restructured Loan) និងបុនហិរញ្ញប្បទាន (Refinancing) ដោយមានចុះហត្ថលេខា និង/ឬស្នាមផ្តិតមេដៃ ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ តទៅ។

**ប្រការ ៦.-**

គ្រឹះស្ថានដែលមិនគោរពតាមខ្លឹមសារនៃប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៧.-**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

អគ្គលេខាធិការ អគ្គនាយកបច្ចេកទេស អគ្គនាយកត្រួតពិនិត្យ អគ្គបេឡា អគ្គពិនិត្យ ប្រធាននាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាដែលមានការពាក់ព័ន្ធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។៚

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

**ទេសាភិបាល**

**ជា.ចាន់តូ**

**កន្លែងទទួល៖**

- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន៖**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការដាក់ពិដានអត្រាការប្រាក់ឥណទាន

ដើម្បីរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការការពារផលប្រយោជន៍ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋក្រីក្រ ទប់ស្កាត់បំណុលវ័ណ្ឌក និងកាត់បន្ថយភាពក្រីក្រ ការពារអតិថិជនពីការគិតការប្រាក់ក្នុងអត្រាខ្ពស់ពេកពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងជំរុញការប្រើប្រាស់ឥណទានឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្តល់ឥណទានពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយមានការប្រុងប្រយ័ត្នខ្ពស់ជាងមុន ធនាគារជាតិនៃកម្ពុជាសម្រេចដាក់ពិដានអត្រាការប្រាក់ទៅលើឥណទានដែលផ្តល់ឱ្យដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់។

ពិដានអត្រាការប្រាក់ឥណទានមានកម្រិត ១៨% ក្នុងមួយឆ្នាំ ហើយនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៧ នេះតទៅជាកំហិត។ ការដាក់ពិដានឥណទាននេះ គឺជាការដាក់កម្រិតអតិបរមានៃអត្រាការប្រាក់ឥណទាន ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ អាចកំណត់យកពីអតិថិជនដែលខ្ចីប្រាក់ពីគ្រឹះស្ថាន។ ចំពោះខ្លឹមសារលម្អិត សូមអានប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧.០១៧.១០៩ ប្រ.ក ស្តីពីការដាក់ពិដានអត្រាការប្រាក់ឥណទានចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh

ធ៧-០៦-១០១ ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំ រេ ច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវគោលកាណ៍ណែនាំសំរាប់ការគ្រប់គ្រង លើប្រព័ន្ធចែករំលែកព័តិមានឥណទានដែល មានខ្លឹមសារដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន។

**ប្រការ ៣.-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ, ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០០៦

**ទេសាភិបាល**

ហត្ថលេខា និងត្រា **ជា ចាន់តូ**

# ឧបសម្ព័ន្ធទី១ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

# គោលការណ៍ណែនាំ

# ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

## I- គោលបំណង

គោលការណ៍ណែនាំការគ្រប់គ្រងនេះ តទៅនេះហៅថា "**គោលការណ៍ណែនាំ**" មានគោលបំណងដាក់ចេញវិធានគ្រប់គ្រងរបៀបរបបធ្វើការងាររបស់ទីភ្នាក់ងារនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលបង្កើតឡើងតាមបញ្ញត្តិនៃប្រកាសស្តីពីការប្រើប្រាស់ និងការការពារព័ត៌មានឥណទាន តទៅនេះហៅថា "**ប្រកាស**" ។

## II- ភាគីដែលអាចអនុវត្តបាន

គោលការណ៍ណែនាំនេះអនុវត្តបានចំពោះក្រុមប្រឹក្សាភិបាល គណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## III- ក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ការិយាល័យរបស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្ថិតនៅធនាគារជាតិនៃកម្ពុជា ។

១- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានរួមមាន ប្រធាន ១រូប និងសមាជិកពី ៦ ទៅ ៨រូប មកពីធនាគារជាសមាជិក និងទីភ្នាក់ងារ ។

២- ធនាគារជាតិនៃកម្ពុជាត្រូវចាត់តាំងប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានឱ្យធ្វើជាតំណាង និងទទួលបន្ទុកប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៣- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវតែងតាំងនាយក ។ ប៉ុន្តែច្រើនជាងមួយភាគបីនៃនាយកទាំងអស់ត្រូវតែងតាំងបេក្ខជនមកពីធនាគារជាសមាជិក ។

៤- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវតែងតាំងប្រធានគណៈកម្មាធិការគ្រប់គ្រង ប្រធានដឹកនាំក្រុមប្រតិបត្តិ និងសមាជិកប្រព័ន្ធចែករំលែកព័ត៌មានឥណទានផ្សេងទៀត ។

៥- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែជាសមាជិកនៃក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយស្វ័យប្រវត្តិ ។ នៅពេលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអវត្តមាន ប្រធានគណៈកម្មាធិការគ្រប់គ្រងជាអ្នកដឹកនាំជំនួស ។

៦- តំណែងប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានអាណត្តិ ២ឆ្នាំ ហើយអាចតែងតាំងជាថ្មីបាន ។

៧- ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចប្រព្រឹត្តទៅបានដោយមានវត្តមានសមាជិកពាក់កណ្តាល ឬច្រើនជាងនេះនៃសមាជិកក្នុងបញ្ជី និងសំរេចចិត្តដោយមតិភាគច្រើន (ចាប់ពីពាក់កណ្តាល ឬច្រើនជាងនេះ) នៃចំនួនសមាជិកដែលមានវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមភាព ។

៨- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវមើលការខុសត្រូវលើប្រតិបត្តិការ និងការអនុវត្តន៍របស់ទីភ្នាក់ងារ ដើម្បីធានាសុវត្ថិភាពមូលដ្ឋានទិន្នន័យព័ត៌មានឥណទាន ប្រសិទ្ធភាព និងភាពសមរម្យនៃវិធានការរបស់ទីភ្នាក់ងារ និងការអនុវត្តន៍តាមក្រមប្រតិបត្តិរបស់សមាជិក ។

៩- ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់វិធានការចំពោះការប្រព្រឹត្តិល្មើសនឹងប្រកាស និងក្រមប្រតិបត្តិ តាមរយៈការត្រួតពិនិត្យទ្បេងទាត់ និង/ឬ តាមរយៈការត្រួតពិនិត្យពិសេស ។

១០- បន្ទាប់ពីទទួលបានការយល់ព្រមលើកាលកំណត់ដំបូង (ឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ) ពីធនាគារជាតិនៃកម្ពុជា ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវរៀបចំ និងចេញប្រកាស ពិន័យ និងកាលកំណត់បង់សងពិន័យក្នុងនាមប្រធានរបស់ខ្លួនចំពោះរាល់បទល្មើសបំពានលើប្រកាស និងក្រមប្រតិបត្តិ។ ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចកែប្រែការផាកពិន័យនិងកាលកំណត់បង់សងពិន័យបាន។ ការពិន័យនិងកាលកំណត់បង់សងពិន័យដែលក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានកែប្រែថ្មី មានប្រសិទ្ធភាពដូចកាលកំណត់ដំបូង ដែលធនាគារជាតិនៃកម្ពុជាបានយល់ព្រមដែរ ហើយត្រូវជូនដំណឹងដល់ធនាគារជាសមាជិកភ្លាមៗ ។

## IV- បញ្ហាសំរាប់ការពិគ្រោះយោបល់របស់ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចេញសេចក្តីសំរេចចិត្តដោយពិគ្រោះយោបល់គ្នាចំពោះចំណុចមួយចំនួនខាងក្រោម :

១- បញ្ហាទាក់ទងនឹងប្រភេទព័ត៌មានឥណទានសំខាន់ៗ ដែលទីភ្នាក់ងារប្រមូលយក និងរយៈពេលរក្សាទុក និងកំរិតអប្បបរមា នៅក្រោមបញ្ញត្តិនៃប្រកាស និងក្រមប្រតិបត្តិដែលអាចយកមកអនុវត្តបាន

២- បញ្ហាទាក់ទងនឹងការទទួល/ការចែករំលែកនិងការទូទាត់ចំណាយប្រតិបត្តិការដែលកើតឡើងក្នុងដំណើរការនៃការប្រមូលមជ្ឈការការគ្រប់គ្រងនិងការប្រើប្រាស់ព័ត៌មានឥណទានដោយទីភ្នាក់ងារ និងការវិនិយោគលើគំរោងថ្មី

៣- បញ្ហាទាក់ទងនឹងការស៊ើបអង្កេត លក្ខខណ្ឌជាក់ស្តែងនៃការអនុវត្តន៍តាមភារកិច្ចនៃគ្រឹះស្ថានហិរញ្ញវត្ថុ ដើម្បីផ្តល់ព័ត៌មានឥណទាន និងដាក់ពិន័យ

៤- ចំណុចជាក់លាក់ចាំបាច់សំរាប់ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

## V- គណៈកម្មាធិការគ្រប់គ្រង

១- គណៈកម្មាធិការគ្រប់គ្រងមានសមាសភាពពី ៣ ទៅ ១០ រូប ដោយមានប្រធាន ១រូប សមាជិកអចិន្ត្រៃយ៍យ៉ាងហោច ២រូប មកពីធនាគារជាតិនៃកម្ពុជា និងសមាជិកមិនអចិន្ត្រៃយ៍មកពី :

- នាយកចាត់ការនាយកដ្ឋានឥណទានរបស់ធនាគារជាសមាជិក
- តំណាងតែងតាំងដោយសមាគមធនាគារនៅកម្ពុជា
- បុគ្គលដទៃទៀតដែលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានបានស្នើឡើង។

២- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ជាអ្នកតែងតាំងប្រធានគណៈកម្មាធិការគ្រប់គ្រង ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រងមានអាណត្តិ ២ឆ្នាំ ហើយអាចតែងតាំងជាថ្មីបាន ។

៤- ប្រធានគណៈកម្មាធិការគ្រប់គ្រងជាអ្នកជ្រើសតាំងសមាជិក ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាអ្នកតែងតាំងប្រធាន ។

៥- ការប្រជុំគណៈកម្មាធិការគ្រប់គ្រងអាចកោះហៅ ឬតាមសំណើរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រង តាមរយៈសំណើ ១ ភាគ ៣ ឬច្រើនជាងនេះនៃសមាជិកចុះបញ្ជី ក្នុងករណីចាំបាច់ ។

៦- ការប្រជុំគណៈកម្មាធិការគ្រប់គ្រងអាចប្រព្រឹត្តទៅបានដោយមានវត្តមានសមាជិកពាក់កណ្តាល ឬច្រើនជាងនេះនៃសមាជិកក្នុងបញ្ជី និងសំរេចចិត្តដោយមតិភាគច្រើនចាប់ពីពាក់កណ្តាល ឬ ច្រើនជាងនេះនៃសមាជិកដែលមានវត្តមាន។

## VI- បញ្ហាសំរាប់ការប្រឹក្សាយោបល់របស់គណៈកម្មាធិការគ្រប់គ្រង

គណៈកម្មាធិការគ្រប់គ្រងរៀបចំផែនការ និងសំរេចចិត្តដោយការពិគ្រោះយោបល់គ្នា ចំពោះចំណុចមួយចំនួនខាងក្រោមៈ

១- បញ្ហាទាក់ទងនឹងប្រភេទព័ត៌មានឥណទានសំខាន់ៗ ដែលភ្នាក់ងារប្រមូលយក និងរយៈពេលរក្សាទុក និងកំរិតអប្បបរមា នៅក្រោមបញ្ញត្តិនៃប្រកាស និងក្រមប្រតិបត្តិដែលអាចយកមកអនុវត្តបាន (មុននឹងអនុវត្តផែនការ ត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)។

២- បញ្ហាទាក់ទងនឹងការទទួល ការចែករំលែក និងការទូទាត់ចំណាយប្រតិបត្តិការដែលកើតឡើងក្នុងដំណើរការនៃការប្រមូលមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទានដោយទីភ្នាក់ងារ និងការវិនិយោគលើគំរោងថ្មី (មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សា-ភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)។

៣- បញ្ហាទាក់ទងនឹងការស៊ើបអង្កេតលក្ខខណ្ឌជាក់ស្តែងនៃការអនុវត្តន៍តាមភារកិច្ចរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុជាសមាជិក ដើម្បីផ្តល់ព័ត៌មានឥណទាន និងដាក់ពិន័យ (មុននឹងអនុវត្តផែនការត្រូវទាមទារឱ្យមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាមុនសិន)។

៤- បញ្ហាទាក់ទងនឹងវិធានការទប់ស្កាត់ ករណីប្រើប្រាស់ខុស និងការលេចធ្លាយព័ត៌មានឥណទានសំរាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងពីប្រកាសអនុញ្ញាត ។

៥- ចំណុចជាក់លាក់ចាំបាច់សំរាប់ការប្រមូលមជ្ឈការ ការគ្រប់គ្រង និងការប្រើប្រាស់ព័ត៌មានឥណទាន និងការត្រួតពិនិត្យរបស់ក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## VII- **កិច្ចការរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រង**

១- ប្រធានគណៈកម្មាធិការគ្រប់គ្រងជាតំណាងឱ្យគណៈកម្មាធិការគ្រប់គ្រង ជំនួសប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ពេលប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអវត្តមាន និងជាអ្នកដឹកនាំការងារប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំថ្ងៃ ។

២- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវតែងតាំងលេខាប្រតិបត្តិ ១រូប ក្នុងចំណោមសមាជិកអចិន្ត្រៃយ៍ ដើម្បីជួយសំរួលសកម្មភាពរបស់គណៈកម្មាធិការគ្រប់គ្រង និងការប្រាស្រ័យទាក់ទងរវាងគណៈកម្មាធិការគ្រប់គ្រង និងក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។ លេខាប្រតិបត្តិត្រូវរាយការណ៍អំពីកំណត់ហេតុប្រជុំទៅឱ្យសមាជិកគណៈកម្មាធិការគ្រប់គ្រង ក៏ដូចជាទៅឱ្យតំណាងរបស់ធនាគារជាសមាជិក និងគ្រឹះស្ថានហិរញ្ញវត្ថុ ដែលចូលរួមផ្តល់ព័ត៌មានឥណទាននៅពេលណាដែលពាក់ព័ន្ធ និងរក្សាទុកឯកសារដើម និងឯកសារពាក់ព័ន្ធ ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រង ត្រូវជ្រើសតាំងអ្នកដឹកនាំក្រុមប្រតិបត្តិនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ១រូប ដើម្បីឱ្យប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម តែងតាំង ។

៤- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំផែនការថវិកាប្រចាំឆ្នាំ ដោយមានជំនួយពីអ្នកដឹកនាំក្រុមប្រតិបត្តិ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម ។

៥- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំឆ្នាំ ដោយមានជំនួយពីប្រធានក្រុមប្រតិបត្តិ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានអនុម័តយល់ព្រម ។

៦- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំរបាយការណ៍ប្រចាំខែ និងរាយការណ៍ជូនប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៧- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវរៀបចំក្រុមការងារពិសេសមួយ ដើម្បីអនុវត្តការពិគ្រោះយោបល់ប៉ុន្មានចំណុចខាងលើឱ្យមានប្រសិទ្ធភាព ។

VIII- **ក្រុមប្រតិបត្តិ**

១- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវចាត់ចែង និងត្រួតពិនិត្យក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទានដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនូវសូហ្វវែរ (Software) និងហាតវែរ (Hardware) របស់ទីភ្នាក់ងារដែលចាំបាច់សំរាប់ប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានឥណទានប្រចាំថ្ងៃ ។

២- សមាសភាពក្រុមប្រតិបត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន រួមមានប្រធានក្រុមអ្នកគ្រប់គ្រងសេវាតាមប្រព័ន្ធវេបសាយ (web service administrator) អ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យ (database service administrator) និងក្រុមជំនួយការគ្រប់គ្រង ។

៣- ប្រធានគណៈកម្មាធិការគ្រប់គ្រងត្រូវជ្រើសតាំងប្រធានក្រុមប្រតិបត្តិ ក្នុងចំណោមបុគ្គលិកការិយាល័យព័ត៌មានុសាស្ត្ររបស់ទីភ្នាក់ងារ ហើយប្រធានក្រុមប្រឹក្សាភិបាលប្រព័ន្ធចែករំលែកព័ត៌មានឥណទានជាអ្នកតែងតាំង ។

៤- ក្នុងនាមជាអ្នកគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រធានក្រុមប្រតិបត្តិត្រូវគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការប្រចាំថ្ងៃរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានអ្នកគ្រប់គ្រងសេវាវេបសាយ និងអ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យជាជំនួយការ ។

៥- ក្នុងករណីដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទានមានបញ្ហាខូចខាត ប្រធានក្រុមប្រតិបត្តិត្រូវអនុវត្តការស្តារជាបន្ទាន់ និងរាយការណ៍ជូនប្រធានគណៈកម្មាធិការគ្រប់គ្រងអំពីលទ្ធផលភ្លាមៗដែរ ។

៦- អ្នកគ្រប់គ្រងសេវាវេបសាយនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានតួនាទីដូចខាងក្រោម :

- រក្សា និងការពារ web server របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយទប់ទល់នឹងវីរុស (virus) ដែលលួចចូលបំផ្លាញប្រព័ន្ធវេបសាយ (hacker) និងការបាក់បែកខូចខាតសំបកខាងក្រៅ
- គ្រប់គ្រងអត្តសញ្ញាណអ្នកប្រើប្រាស់ធនាគារ (Bank User IDs) ដោយអនុញ្ញាត ព្យួរ ឬលុបចោល និងឆ្លើយតបទូរសារ (e-mail) ជាមួយអ្នកប្រើប្រាស់ ក្នុងករណីមានបំរែបំរួលស្ថានភាពរបស់អ្នកប្រើប្រាស់
- ឆ្លើយតបនឹងសំនួររបស់ធនាគារជាសមាជិក
- ជូនដំណឹងដល់ធនាគារជាសមាជិក អំពីបំរែបំរួលការប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងបំរែបំរួលបទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- ពិនិត្យលើកិច្ចការថែទាំទំព័រ សំណើឆែកឆេរ (Check Request Page) របស់អ្នកចុះបញ្ជីទិន្នន័យធនាគារ (Bank Data Registrant)
- ពិនិត្យលើបន្ទុកប្រព័ន្ធ (system load) និង សកម្មភាពរបស់អ្នកប្រើប្រាស់
- បង្កើតស្ថិតិដែលទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធពាក់ព័ន្ធ
- រក្សាឯកសារបំរុង (back up) តាមកាលកំណត់

- រៀបចំរបាយការណ៍ប្រចាំខែអំពីការប្រព្រឹត្តិខុសច្បាប់ និងបទប្បញ្ញត្តិ ដោយធនាគារជាសមាជិក និងរាយការណ៍ជូនប្រធានក្រុម
- រាយការណ៍រាល់សកម្មភាពសង្ស័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជូនប្រធានក្រុម
- រក្សា និងកែសំរួលក្បួនប្រើប្រាស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (CIS user manuals) សំរាប់ធនាគារជាសមាជិក អ្នកចុះបញ្ជីទិន្នន័យធនាគារ និងអ្នកប្រើប្រាស់ធនាគារ និងក្បួនសំរាប់អ្នកគ្រប់គ្រងសេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៧- អ្នកគ្រប់គ្រងសេវាមូលដ្ឋានទិន្នន័យប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មានតួនាទីដូចខាងក្រោម :

- រក្សា និងការពារ web server របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយទប់ទល់នឹងវីរុស (virus) ដែលលួចចូលបំផ្លាញប្រព័ន្ធវេបសាយ (hacker) និងការបាក់បែកខូចខាតសំបកខាងក្រៅ
- រក្សាឯកសារ back up តាមកាលកំណត់
- រៀបចំឯកសារបំរុងបន្ទាន់ និង ទំរង់ការស្តារ
- ពិនិត្យតាមដានបន្ទុកប្រព័ន្ធ (system load) និង ផែនការសំរាប់តម្រូវការ HDD បន្ថែម
- រាយការណ៍រាល់សកម្មភាពជាប់សង្ស័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជូនប្រធានក្រុម ។

## IX- **ការបញ្ចេញព័ត៌មាន**

ប្រភេទព័ត៌មានស្ថិតិដែលជាសមិទ្ធផលនៃប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងដែលអាចបញ្ចេញឱ្យធនាគារជាសមាជិក និងសាធារណជនដឹង ត្រូវកំណត់ដោយគណៈកម្មាធិការគ្រប់គ្រងតាមប្រកាស និងបទប្បញ្ញត្តិប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

## X- **បទប្បញ្ញត្តិបន្ថែម**

១- គោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទានចូលជាធរមានចាប់ពីថ្ងៃ ខែមិថុនា ឆ្នាំ២០០៦ នេះតទៅ ។

២- ការពិន័យ និងកាលកំណត់បង់សងពិន័យនៅក្នុងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះចូលជាធរមានចាប់ពីពេលចុះហត្ថលេខានេះតទៅ ។

# ឧបសម្ព័ន្ធទី២ នៃប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
# ការពិន័យ និងកាលកំណត់បង់សងពិន័យចំពោះការប្រព្រឹត្តិខុសនឹងក្រមប្រតិបត្តិ

**១- កាលកំណត់ដែលធនាគារជាសមាជិកត្រូវរាយការណ៍អំពីព័ត៌មានឥណទាន**

| ចំណាត់ថ្នាក់ | កាលបរិច្ឆេទរាយការណ៍ |
|---|---|
| ១- ការចុះបញ្ជីព័ត៌មានបំណុលមិនទាន់សង | ថ្ងៃធ្វើការចុងក្រោយនៃខែ |
| ២- ការចុះបញ្ជីព័ត៌មានបំណុលដែលខកខានមិនបានសង | ថ្ងៃធ្វើការបន្ទាប់ បន្ទាប់ពីពេលដែលមូលប្បទានប័ត្រ ឬវិក័យប័ត្រត្រូវបានគេបដិសេធ ហើយប្រកាសជា "ការខកខានមិនបានសងជាលើកចុងក្រោយ" |
| ៣- ការចុះបញ្ជីនៃការឱ្យរួចបំណុល | ថ្ងៃធ្វើការចុងក្រោយនៃខែ ដែលរកឃើញហេតុផលឱ្យរួចបំណុល |
| ៤- ការឆ្លើយតបនឹងសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីទទួលសំណើសុំផ្ទៀងផ្ទាត់ |

**២- កាលកំណត់ពិន័យក្នុងករណីពន្យារ និងលុបចោល ការឱ្យរួចបំណុលមិនត្រឹមត្រូវ និងការធ្វេសប្រហែស**

| ប្រភេទ | លក្ខណៈវិនិច្ឆ័យ | ពិន័យ | កំណត់សំគាល់ |
|---|---|---|---|
| ១- ការពន្យារ ឬការលុបចោលព័ត៌មានបំណុលមិនទាន់សង បំណុលដែលខកខានមិនបានសង និងការឱ្យរួចបំណុល | ៣០ថ្ងៃ និងតិចជាង | ៤.០០០រៀល | ក្នុង១ករណី |
| | ៦០ថ្ងៃ និងតិចជាង | ៨.០០០រៀល | |
| | ១៨០ថ្ងៃ និងតិចជាង | ១២.០០០រៀល | |
| | លើសពី១៨០ថ្ងៃ | ១៦.០០០រៀល | |
| ២- ការឱ្យរួចបំណុលមិនត្រឹមត្រូវនៃព័ត៌មានឥណទានអវិជ្ជមាន | | ១០០.០០០រៀល | ក្នុង១ករណី |
| ៣- ការធ្វេសប្រហែសក្នុងការដោះស្រាយសំណើសុំផ្ទៀងផ្ទាត់/កែតម្រូវ | ៧ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើសុំផ្ទៀងផ្ទាត់ /កែតម្រូវ | ២០.០០០រៀល | ក្នុង១ករណី |
| | ១៤ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើសុំផ្ទៀងផ្ទាត់ /កែតម្រូវ | ៤០.០០០រៀល | |
| | ៣០ថ្ងៃនិងច្រើនជាង បន្ទាប់ពីទទួលបានសំណើ សុំផ្ទៀងផ្ទាត់ /កែតម្រូវ | ៨០.០០០រៀល | |

៣- ប្រធានក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវជូនដំណឹងអំពីការពិន័យដែលរំពឹងនឹងធ្វើដល់ធនាគារជាសមាជិកជាប្រចាំខែ ។ ធនាគារជាសមាជិកអាចសរសេរលិខិតបដិសេធការពិន័យរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយភ្ជាប់ឯកសារភស្តុតាងមកជាមួយក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីទទួលបានការជូនដំណឹងពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។

៤- ប្រព្រឹត្តិកម្មក្នុងថេរៈវេលានៃការអនុគ្រោះ ៖ ក្នុងអំឡុងពេលនៃការសាកល្បងគំរោងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន (២០០៦-២០០៧) បើចំនួនករណីពន្យារ និងលុបចោល ( ប្រភេទ១ នៃចំនុចទី ២ នៃឧបសម្ព័ន្ធនេះ) តិចជាង ១០ ករណីក្នុងមួយខែ ត្រូវឱ្យរួចពីកាលកំណត់ពិន័យក្នុងចំនុចទី២នៃឧបសម្ព័ន្ធនេះ ។ បើចំនួនករណីពន្យារ និងលុបចោលលើសពី ១០ ករណីនោះចំនួន ១០ ករណីត្រូវដកចេញពីចំនួនករណីសរុបក្នុងការគណនាចំនួនពិន័យ ។

ធ៧-០១-១១៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការគណនាការប្រាក់ចំពោះឥណទានមីក្រូហិរញ្ញវត្ថុ

**ប្រការ ១**.-

ធនាគារឯកទេសឥណទានជនបទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលបានចុះបញ្ជីនិងបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងសមាគមចំណុះច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវធ្វើការគណនាការប្រាក់លើឥណទានរបស់ខ្លួនឱ្យបានស្របតាមខ្លឹមសារនៃប្រកាសនេះ។

**ប្រការ ២**.-

ការប្រាក់ចំពោះឥណទានដែលបានផ្តល់ឱ្យតាមខ្លឹមសារនៃប្រកាសនេះ ត្រូវគណនាដោយផ្អែកលើមូលដ្ឋាននៃចំនួនប្រាក់ឥណទានដែលបានផ្តល់ដោយដកចេញនូវចំនួនប្រាក់ដើមដែលបានសងហើយបានន័យថា ការប្រាក់លើឥណទានសម្រាប់រយៈពេលមួយជាកំណត់ (សប្តាហ៍ ខែ ត្រីមាស ឆ្នាំ តាមករណីនីមួយៗ) ត្រូវគណនាលើមូលដ្ឋាននៃសមតុល្យឥណទានក្នុងរយៈពេលនោះ។

**ប្រការ ៣**.-

កិច្ចសន្យារវាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងអតិថិជនត្រូវមានបង្ហាញតារាងពីការសងរំលោះឥណទាន។

**ប្រការ ៤**.-

គ្រឹះស្ថានចំណុះច្បាប់ណាដែលមិនគោរពតាមប្រកាសនេះ នឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**ប្រការ ៥**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៧**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០១

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**

# ឧបសម្ព័ន្ធទី២

# គំរូកិច្ចសន្យាខ្ចីបរិភោគ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គំរូ

# កិច្ចសន្យាខ្ចីបរិភោគ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................................ភេទ...........អាយុ...........អត្តសញ្ញាណប័ណ្ណលេខ..................អាសយដ្ឋានផ្ទះលេខ.......ផ្លូវលេខ..........ភូមិ.............សង្កាត់..........ខណ្ឌ..........ក្រុង.........មុខរបរ...........ចាប់ពីពេលនេះទៅហៅថាភាគី«ក» លេខទូរស័ព្ទ...................................។

និង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ................អាយុ..................អត្តសញ្ញាណប័ណ្ណលេខ............អាសយដ្ឋានផ្ទះលេខ.......ផ្លូវលេខ......ភូមិ.............សង្កាត់..........ខណ្ឌ..........ក្រុង.......មុខរបរ...........ចាប់ពីពេលនេះទៅហៅថាភាគី«ខ» លេខទូរស័ព្ទ...................................។

ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចខាងក្រោម៖

**ប្រការ ១ ៖** ភាគី«ខ»ស្នើរសុំខ្ចីប្រាក់ពីភាគី«ក»ចំនួន...................................................ហើយភាគី«ក»ក៏យល់ព្រមតាមសំណើររបស់ភាគី«ខ»។

**ប្រការ ២ ៖** ដើម្បីធានាដល់ការអនុវត្តតព្វកិច្ចភាគី «ខ» បានយកប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ..........................ចេញដោយ..............................មានទីតាំងស្ថិតនៅផ្ទះលេខ..............ផ្លូវលេខ............ភូមិ.....................សង្កាត់..................ខណ្ឌ.......................ក្រុង.........................មកទុកនៅភាគី«ក»ចាប់ពីថ្ងៃទី.........ខែ.............ឆ្នាំ.................។

**ប្រការ ៣ ៖** រយៈពេលនៃការខ្ចីមានចំនួន............គិតចាប់ពីថ្ងៃទី.............ខែ............ឆ្នាំ................ដល់ថ្ងៃទី.............ខែ............ឆ្នាំ.................។

**ប្រការ៤ ៖** ការកំណត់អត្រាការប្រាក់:

ភាគីទាំងពីរបានព្រមព្រៀងគ្នាកំណត់អត្រាការប្រាក់ដូចតទៅ:

ក្នុងរយៈពេល១ខែភាគី «ខ» ត្រូវបង់នូវការប្រាក់ចំនួន........................ចំនួន.......................ភាគរយ

ដែលមានតម្លៃស្មើរនឹង....................ទៅឲ្យភាគី«ក»ទីកន្លែងប្រគល់ការប្រាក់គឺ ទីលំនៅដ្ឋានរបស់ភាគី «ក» ឬកន្លែងដទៃទៀតតាមការព្រមព្រៀងរបស់ភាគីទាំងពីរ ។

**ប្រការ ៥ ៖** ការប្រាក់ត្រូវបង់ឲ្យបានទៀងទាត់ជារៀងរាល់ខែ ។ ករណីមានការបង់ការប្រាក់មានការយឺតយ៉ាវ ( ដែលមានរយៈពេលលើសពី.......................) ភាគី«ក»មានសិទ្ធិធ្វើការដាស់តឿនភាគី «ខ» ក្នុងអំឡុងពេល...........................ថ្ងៃដែលគិតចាប់ពីថ្ងៃទី...........ខែ..........ឆ្នាំ...........ដល់ថ្ងៃទី........ខែ........ ឆ្នាំ...........។

ករណីដែលដល់ពេលកំណត់ នៃការដាស់តឿនហើយភាគី«ខ»នៅតែមិនព្រមបង់ការប្រាក់ទៀតនោះក្នុងរយៈពេល១ឆ្នាំក្រោយមកគិតពីថ្ងៃចុះកិច្ចសន្យា ភាគី«ក»មានសិទ្ធិបូកចំនួនការប្រាក់នេះនឹងប្រាក់ដើមបាន ។

**ប្រការ ៦ ៖** ការសងប្រាក់ដើមៈ

- ការសងប្រាក់ដើមរបស់ភាគី«ខ»ត្រូវសងនៅថ្ងៃទី................ខែ............ឆ្នាំ...........។
- ទីកន្លែងនៃការសងប្រាក់គឺទីលំនៅដ្ឋានរបស់ភាគី«ក»ឬកន្លែងដទៃទៀតតាមការព្រមព្រៀងរបស់ភាគីទាំងពីរ ។

**ប្រការ ៧ ៖** កាលបើដល់ពេលកំណត់សងប្រាក់ដើមហើយ បើភាគី «ខ» បានយកប្រាក់ដើមចំនួន..................និងការប្រាក់ចំនួន.....................សងដល់ភាគី«ក»នៅពេលដែលភាគី«ក»បានទទួលនូវប្រាក់គ្រប់ចំនួនហើយភាគី«ក»ត្រូវប្រគល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ.....................ចេញដោយ...................................ឲ្យទៅភាគី«ខ»វិញ ។

**ប្រការ ៨ ៖** ករណីដែលពេលកំណត់សងប្រាក់ដើមហើយ បើភាគី «ខ» មិនបានយកប្រាក់ដើមចំនួន......................សងទៅភាគី«ក»ទេនោះ ភាគី«ក»មានសិទ្ធិរក្សាទុកនូវប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ................ចេញដោយ....................សិនហើយភាគី«ក»មានសិទ្ធិធ្វើការដាស់តឿនភាគី«ខ»នៅក្នុងរយៈពេល........................ថ្ងៃ ។ គិតចាប់ពីថ្ងៃទី...........ខែ.............ឆ្នាំ.............ដល់ ថ្ងៃទី...........ខែ......ឆ្នាំ........។

បើដល់ពេលកំណត់ហើយ នៃការដាស់តឿនហើយភាគី«ខ»នៅតែមិនសងប្រាក់ដើមទៀតភាគី«ក»នឹងចាត់វិធានការណ៍ទៅតាមនីតិវិធីច្បាប់ ។

**ប្រការ ៩៖** ភាគីទាំងពីរ ត្រូវអនុវត្តកាតព្វដូចមានចែង នៅក្នុងប្រការទាំងអស់ខាងលើ ដោយឆន្ទៈសុចរិត ដោយតម្លាភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

កិច្ចសន្យានេះ ធ្វើឡើងជាភាសាខ្មែរមានចំនួន ០៥ច្បាប់ ។ ០១ ច្បាប់រក្សានៅភាគី«ក» និង ០១ច្បាប់រក្សានៅភាគី«ខ» និង០២ច្បាប់ទៀតរក្សាទុកនៅសាក្សីម្នាក់មួយច្បាប់ និង ០១ ច្បាប់ទៀតរក្សានៅទុកនៅសង្កាត់.................................ដែលជាទីតាំងស្ថិតនៅរបស់អចលនវត្ថុធានានោះ ។

កិច្ចសន្យានេះ បានធ្វើឡើងដោយការព្រមព្រៀងពិតប្រាកដ និងដោយសេរី គឺមិនមានការបង្ខិតបង្ខំ និងគំរាមកំហែង ឬការប្រើអំពើហឹង្សាឡើយ ម៉្យាងទៀតកិច្ចសន្យានេះ បានបង្កើតឡើងនៅពេលដែលគូភាគីទាំងពីមានសតិ និងស្មារតីគ្រប់គ្រាន់ ហើយបានពិនិត្យយ៉ាងត្រឹមត្រូវ ។

កិច្ចសន្យានេះមានសុពលភាពអនុវត្ត ចាប់ពីពេលដែលភាគីទាំងពីរបានចុះហត្ថលេខា ឬផ្តិតមេដៃទទួលយល់ព្រមនេះតទៅ ។

ធ្វើនៅ.............ថ្ងៃទី......ខែ...........ឆ្នាំ.........

| | | |
|---|---|---|
| ស្នាមមេដៃស្តាំភាគី«ខ» | សាក្សី | ស្នាមមេដៃស្តាំភាគី«ក» |
| ឈ្មោះ...................... | មេធាវី.......................... | ឈ្មោ................... |
| | ត្រាមេធាវី | |

បានឃើញ និង ឯកភាព

ថ្ងៃទី......ខែ........ឆ្នាំ...................

មេឃុំ

ឈ្មោះ.................................. ត្រាមេឃុំ

ប្រភព « *កិច្ចសន្យាពិសេស* » របស់លោក អៀង សំណាង បោះពុម្ពឆ្នាំ២០១៤

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### **កិច្ចសន្យាធានាការខ្ចីប្រាក់** ( បុគ្គលធានា )

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ.............អាយុ............អត្តសញ្ញាណប័ណ្ណលេខ.............អាសយដ្ឋានផ្ទះលេខ...........ផ្លូវលេខ............ភូមិ.................សង្កាត់.....................ក្រុង................លេខទូរស័ព្ទ......................។ មុខរបរ........................តួនាទីជា...........................ធ្វើនៅ................ប្រាក់ចំណូលប្រចាំខែ......................លេខទំនាក់ទំនងកន្លែងធ្វើការ.................។

ខ្ញុំបាទ/នាងខ្ញុំ យល់ព្រមធានាអះអាងដូចតទៅ:

**ប្រការ ១៖** ឈ្មោះ.............................ភេទ.......អាយុ........អត្តសញ្ញាណប័ណ្ណលេខ......................មានអាសយដ្ឋានផ្ទះលេខ.........ផ្លូវ......ភូមិ.......សង្កាត់...........ខណ្ឌ.................ក្រុង.....................ត្រូវជា...................របស់ខ្ញុំបាទ/នាងខ្ញុំ ។

**ប្រការ ២៖** ខ្ញុំបាទ/នាងខ្ញុំសូមទទួលស្គាល់បំណុលដែលឈ្មោះ...................បានខ្ចីប្រាក់ពី.............ចំនួន...............ដែលមាន..............កាលបរិច្ឆេទនៃកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី............ខែ...............ឆ្នាំ............ពី................ពិតប្រាកដមែន ។

**ប្រការ ៣៖** ករណីដែលឈ្មោះ....................................មានចេតនាទុច្ចរិតណាមួយ ឬ រត់គេចខ្លួន ឬខ្វះលទ្ធភាពសងប្រាក់ទៅក្រុមហ៊ុនវិញនោះខ្ញុំបាទ/នាងខ្ញុំ សូមធានាសងបំណុលទាំងអស់នោះជំនួសឈ្មោះ.....................ដោយឥតលក្ខខណ្ឌអ្វីទាំងអស់ ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថា នឹងអនុវត្តកាតព្វកិច្ចខាងលើដោយស្មារតីទទួលខុសត្រូវខ្ពស់ ករណីមានចេតនាទុច្ចរិតណាមួយ ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

ធ្វើនៅ...........ថ្ងៃទី........ខែ..........ឆ្នាំ.............

ឯកសារភ្ជាប់មក: ស្នាមមេដៃស្តាំអ្នកធានា

- អត្តសញ្ញាណប័ណ្ណថតចម្លង ១ច្បាប់
- សៀវភៅគ្រួសារថតចម្លង ១ច្បាប់

ឈ្មោះ.....................

ប្រភព « *កិច្ចសន្យាពិសេស* » របស់លោក អៀង សំណាង បោះពុម្ពឆ្នាំ២០១៤